

# គោលការណ៍ណែនាំស្តីពី ការមិនបង្កគ្រោះថ្នាក់សម្រាប់ ធ្វើការជាមួយជនដែលត្រូវគេជួញដូរ

## ការអនុវត្តកម្មវិធី ASEAN-ACT ប្រកបដោយបរិយាប័ន្ន

*ខែឧសភា ឆ្នាំ២០២១*

Australian Aid | ASEAN-Australia Counter Trafficking

កម្មសិទ្ធិបញ្ញានៃឯកសារទាំងស្រុង និងគ្រប់ផ្នែកនៃឯកសារនេះ (លើកលែងតែនិមិត្តសញ្ញាជំនួយអូស្ត្រាលី និងកន្លែងផ្សេងទៀតដែលត្រូវបានកត់សម្គាល់) គឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុន Cardno និងមិនអាចត្រូវបានប្រើប្រាស់ លក់ ផ្ទេរ ថតចម្លងឬផលិតឡើងវិញទាំងស្រុងឬជាផ្នែកក្នុងលក្ខណៈឬទម្រង់ណាមួយ ឬនៅក្នុង ឬនៅលើប្រពន្ធផ្សព្វផ្សាយណាមួយ ចំពោះបុគ្គលណាម្នាក់ ក្រៅពីដោយមានកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន Cardno ឡើយ។

ឯកសារនេះត្រូវបានផលិតដោយក្រុមហ៊ុន Cardno ដើម្បីផលប្រយោជន៍ និងការប្រើប្រាស់របស់អតិថិជន ដោយអនុលោមទៅនឹងលក្ខខណ្ឌនៃការចូលរួម។ ក្រុមហ៊ុន Cardno មិនត្រូវមានទំនួលខុសត្រូវអ្វីទាំងអស់ចំពោះភាពគីទីបីណាមួយ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ ឬចំពោះការពឹងផ្អែករបស់ភាគីទីបីទៅលើខ្លឹមសារនៃឯកសារនេះឡើយ។

សេចក្តីប្រកាសបដិសេធ: រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់មូលនិធិចំពោះការរៀបចំឯកសារនេះ តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនៈនានាដែលមាននៅក្នុងឯកសារនេះ គឺជារបស់អ្នកនិពន្ធប៉ុណ្ណោះ និងមិនមែនជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីឡើយ។

សេចក្តីថ្លែងអំណរគុណ៖ ឯកសារនេះត្រូវបានសង្ខេបផ្អែកតាមឯកសារគោលការណ៍ណែនាំស្តីពីការមិនបង្កគ្រោះថ្នាក់សម្រាប់ធ្វើការងារជាមួយជនដែលត្រូវបានជួញដូរ ដោយមានការគាំទ្រពីទីប្រឹក្សា ASEAN-ACT និងទីប្រឹក្សាយេនឌ័រអន្តរជាតិ Froniga Greig។

## តើត្រូវប្រើប្រាស់គោលការណ៍ណែនាំនេះ យ៉ាងដូចម្ដេច?

គោលការណ៍ណែនាំនេះមានបួនផ្នែក ដែលអាចត្រូវអានរួមគ្នា ឬដោយឡែកពីគ្នាបាន។ ផ្នែកនីមួយៗផ្ដល់នូវទិដ្ឋភាពទូទៅមួយអំពីការបង្កគ្រោះថ្នាក់ដែលអាចកើតឡើង និងបញ្ជីនៃគន្លឹះអំពីរបៀបមិនបង្កគ្រោះថ្នាក់។ មានការផ្ដល់ដំបូន្មានជាក់លាក់នៅក្នុងវិស័យដូចខាងក្រោម៖

- ការកំណត់អត្តសញ្ញាណជនរងគ្រោះ
- ការធ្វើការងារជាមួយកុមារ
- ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ
- ការធ្វើការងារជាមួយក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់

ឧបសម្ព័ន្ធមួយនឹងផ្ដល់នូវករណីសិក្សាចំនួនប្រាំមួយ ដែលជាឧទាហរណ៍អំពីរបៀបប៉ាន់ប្រមាណ និងកាត់បន្ថយការបង្កគ្រោះថ្នាក់ដែលអាចកើតឡើងនៅក្នុងលក្ខណៈអនុវត្តជាក់ស្ដែង នៅពេលធ្វើការងារជាមួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

## តើការមិនបង្កគ្រោះថ្នាក់គឺជាអ្វី?

ការមិនបង្កគ្រោះថ្នាក់ គឺជាគោលការណ៍មួយ ដែលបានខ្ចីពីសម្បថផ្នែកសីលធម៌ ( Hippocratic Oath ) សម្រាប់វិស័យវេជ្ជសាស្ត្រដែលត្រូវបានអនុវត្តចំពោះវិស័យដទៃទៀត ដូចជា អភិវឌ្ឍន៍អន្តរជាតិជាដើម។ អភិក្រមមិនបង្កគ្រោះថ្នាក់ទទួលស្គាល់ថា វិធានការមានចេតនាល្អដែលត្រូវបានរៀបចំឡើងដើម្បីជួយ អាចបង្កគ្រោះថ្នាក់ដោយចៃដន្យ និងតម្រូវថា អ្នកអនុវត្តការងារត្រូវកំណត់ និងកាត់បន្ថយការបង្កគ្រោះថ្នាក់ដែលអាចកើតឡើង។ ការមិនបង្កគ្រោះថ្នាក់មានលក្ខណៈដូចគ្នាច្រើនមួយនឹងអភិក្រមផ្អែកលើសិទ្ធិមនុស្ស អភិក្រមដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ និងអភិក្រមបរិយាប័ន្នសង្គម។ ការមិនបង្កគ្រោះថ្នាក់លើកកម្ពស់ការមិនរើសអើង និងសារសំខាន់នៃអត្តសញ្ញាណសង្គមនៅក្នុងការស្វែងយល់ និងប៉ាន់ប្រមាណបទពិសោធន៍បុគ្គលពាក់ព័ន្ធនឹងការបង្កគ្រោះថ្នាក់។

## តើការមិនបង្កគ្រោះថ្នាក់មានទំនាក់ទំនងជាមួយអំពើជួញដូរមនុស្សយ៉ាងដូចម្ដេច?

កម្មវិធីប្រឆាំងអំពើជួញដូរមនុស្ស ធ្វើការងារក្នុងកម្រិតខុសៗគ្នាជាមួយជនរងគ្រោះ និងក្រុមដែលងាយរងគ្រោះចំពោះការរើសអើង និងការកេងប្រវ័ញ្ចដោយសារយេនឌ័រ សាសនា ជាតិពន្ធុ កត្តាផ្លូវភេទ ស្ថានភាពទេសន្តរប្រវេសន៍ ឬអាយុរបស់ពួកគេ។[1] ការបង្កគ្រោះថ្នាក់អាចកើតឡើងនៅជំហាននីមួយៗនៃដំណើរការនេះ ដូចជា៖ ការកំណត់អត្តសញ្ញាណជនរងគ្រោះខុសថាជាជនល្មើស ការមិនផ្ដល់ព័ត៌មានគ្រប់ជ្រុងជ្រោយ និងការបកប្រែភាសានៅក្នុងអំឡុងពេលនៃកិច្ចដំណើរការផ្លូវច្បាប់ និងការបញ្ជូនជនរងគ្រោះត្រឡប់ទៅកាន់កន្លែងដើមរបស់ពួកគេវិញ ថ្វីបើមានហានិភ័យនៃការសងសឹកពីសំណាក់ជនជួញដូរមនុស្សក្ដី។ បុព្វហេតុទូទៅមួយទៀតនៃការបង្កគ្រោះថ្នាក់ដែលអាចកើតឡើង គឺការរៀបចំ និងការអនុវត្តកម្មវិធីចិត្តសង្គម សហគមន៍ និងកម្មវិធីសេដ្ឋកិច្ច/បណ្ដុះបណ្ដាលវិជ្ជាជីវៈមិនគ្រប់គ្រាន់ដែលខកខានក្នុងការពិចារណាអំពីឯកជនភាពអត្តសញ្ញាណសង្គម និងវប្បធម៌ ស្វ័យភាព និងទីភ្នាក់ងារ។[2]

ចាប់ពីអ្នកឆ្លើយតបដំបូង ដែលរួមមានអ្នកអនុវត្តការងារមកពីអង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីអនុវត្តច្បាប់ រហូតដល់ព្រះរាជអាជ្ញា តុលាការ និងអ្នករៀបចំគោលនយោបាយ រាល់កិច្ចខិតខំប្រឹងប្រែងទាំងអស់ត្រូវតែបានធ្វើឡើងដើម្បីជៀសវាងការបង្កគ្រោះថ្នាក់នៅពេលកំពុងការពារ និងជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

គោលការណ៍នៃការមិនបង្កគ្រោះថ្នាក់មួយចំនួន ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស រួមមាន៖

១. ការគោរព និងការការពារសិទ្ធិមនុស្ស
២. ការរក្សាការសម្ងាត់ សិទ្ធិចំពោះឯកជនភាព និងអនាមិកភាព
៣. ព័ត៌មានពេញលេញ និងការយល់ព្រម
៤. ស្វ័យសម្រេច និងការចូលរួម
៥. ការមិនរើសអើង
៦. ការយកចិត្តទុកដាក់ដល់យេនឌ័រ
៧. ឧត្តមប្រយោជន៍របស់កុមារ

គោលការណ៍នៃការមិនបង្កគ្រោះថ្នាក់តម្រូវឱ្យអង្គការ/ស្ថាប័ន ដែលកំពុងផ្ដល់ជំនួយដល់ជនរងគ្រោះដោយអំពើជួញដូរ រួមមាន វិស័យយុត្តិធម៌ អ្នកផ្ដល់សេវារដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងដៃគូអនុវត្ត គ្រឹះស្ថានអប់រំ អ្នកតស៊ូមតិ និងអ្នកស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយ ប៉ាន់ប្រមាណគ្រោះថ្នាក់ដែលអាចកើតឡើង និងផ្ដល់មធ្យោបាយជំនួសជទៃទៀត ដើម្បីកាត់បន្ថយហានិភ័យ។

1 UNODC. Anti-Human Trafficking Manual for Criminal Justice Practitioners: Risk Assessment in Trafficking in Persons Investigation. (New York: 2009) https://www.unodc.org/documents/human-trafficking/TIP_module5_Ebook.pdf

2 Rende Taylor, L. & Latonero, M. Updated Guide to Ethics and Human Rights in Anti-Human Trafficking: Ethical Standards for Working with Migrant Workers and Trafficked Persons in the Digital Age. (Bangkok, Issara Institute: 2018). https://44f2713d-a205-4701-bba3-8d419653b4b6.filesusr.com/ugd/5bf36e_1307f698e5ec46b6b2fc7f4391bff4b6.pdf

# ការកំណត់អត្តសញ្ញាណជនរងគ្រោះ៖ គ្រោះថ្នាក់ដែលអាចកើតឡើង និងគន្លឹះសម្រាប់ការមិនបង្កគ្រោះថ្នាក់

គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់របស់អាស៊ានចែងថា ការកំណត់អត្តសញ្ញាណជនរងគ្រោះយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលា គឺជាការចាំបាច់សម្រាប់សុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ។ ចាំបាច់ត្រូវធានាថាជនល្មើសនៃអំពើជួញដូរអាចត្រូវបានចាប់ខ្លួន និងផ្តន្ទាទោសចំពោះបទល្មើសរបស់ពួកគេផងដែរ។ មានការអំពាវនាវឱ្យមានការរៀបចំយន្តការ និងនីតិវិធី ដើម្បីដឹកនាំ និងសម្របសម្រួលការកំណត់អត្តសញ្ញាណជនរងគ្រោះ។ យន្តការ និងនីតិវិធីទាំងនេះក៏គប្បីត្រូវបានរៀបចំជាបទដ្ឋានរួមនៅទូទាំងតំបន់អាស៊ានផងដែរ។

3 Anti-Slavery International. Human Traffic, Human Rights: Redefining Victim Protection. (London: 2002) http://www.antislavery.org/wp-content/uploads/2017/01/hum_traff_hum_rights_redef_vic_protec_final_full.pdf

4 នេះគឺជាការសង្កេតជាទូទៅនៅក្នុងបណ្តាប្រទេសអាស៊ាន នៅក្នុងរបាយការណ៍រៀបចំផែនទីអ្នកពាក់ព័ន្ធស្តីពីសមភាព និងបរិយាប័ន្នសង្គម ដែលរៀបចំដោយ ASEAN-ACT។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ បរាជ័យក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរ

*ចំណុចនេះអនុវត្តមិនត្រឹមតែចំពោះជន*ដែលទទួលរងការកេងប្រវ័ញ្ចនៅបរទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជនទាំងឡាយដែលជាជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងស្រុកផងដែរ។ អ្នកទាំងឡាយ ដែលមន្ត្រីអនុវត្តច្បាប់មិនបានទទួលស្គាល់ថាអាចត្រូវបានជួញដូរ ប្រឈមនឹងហានិភ័យដូចតទៅ៖ ការបន្តទទួលរងការកេងប្រវ័ញ្ច និងការរំលោភបំពាន ការឃុំខ្លួន ការនិរទេស ការចាត់ទុកថាជាបទល្មើស ការរំលោភសិទ្ធិ ការមិនទទួលបានសេវា និងជំនួយចាំបាច់ ការជួញដូរសារជាថ្មី និងការសងសឹកពីជនជួញដូរ។[3] នៅក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍ជាច្រើន ចំនួនជនរងគ្រោះដោយអំពើជួញដូរយ៉ាងច្រើនសន្ធឹកសន្ធាប់ត្រូវបានកំណត់ថា ជាស្ត្រី ឬកុមារី ស្របពេលដែលបុរស កុមារា ជនមានពិការភាព និងអ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI) កម្រត្រូវបានគេទទួលស្គាល់ណាស់។[4]

**គន្លឹះទី ១៖**

អនុវត្តតាមគោលការណ៍ណែនាំ ឬ បទដ្ឋាននីតិវិធីប្រតិបត្តិការ (SOPs) ជាតិស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការបញ្ជូន។ ប្រើប្រាស់កម្រងសូចនាករ ដែលទទួលស្គាល់ដោយរដ្ឋាភិបាល ឬស្ថាប័ន ដើម្បីជួយកំណត់ថាតើជនម្នាក់គឺជាជនរងគ្រោះដោយអំពើជួញដូរដែរ ឬទេ។ ប្រសិនបើមានការសង្ស័យ សូមពិគ្រោះយោបល់ជាមួយប្រធាន ឬសហការីដែលមានបទពិសោធន៍ និងចំណេះដឹងច្រើនអំពីករណីនេះ។

**គន្លឹះទី ២៖**

ចំណាយពេលដើម្បីប៉ាន់ប្រមាណថា តើជននេះ គឺជាជនរងគ្រោះដោយអំពើជួញដូរឬទេ។ ជនរងគ្រោះដោយអំពើជួញដូរអាចមិនបំពេញតាមសូចនាករទាំងអស់នៃអំពើជួញដូរឡើយ នៅក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យ ឬដំណើរការកំណត់អត្តសញ្ញាណដំបូង ជាពិសេសប្រសិនបើពួកគេមិនមានអារម្មណ៍ថាមានសុវត្ថិភាព ឬសុខស្រួល ឬពួកគេកំពុងទទួលរងការប៉ះទង្គិចផ្លូវចិត្ត។ កុមារ ជនមានពិការភាព និងអ្នកទាំងឡាយដែលមានតម្រូវការពិសេស អាចជួបប្រទះនឹងការលំបាកខ្លាំងក្នុងការប្រាប់ពីបទពិសោធន៍របស់ពួកគេ និងជាលទ្ធផល ពិបាកកំណត់អត្តសញ្ញាណ។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ការចាប់ខ្លួន ការឃុំខ្លួន និងការនិរទេស

ជនរងគ្រោះដោយអំពើជួញដូរ ដែលមិនត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្រប អាចត្រូវរងការចាប់ខ្លួន ការឃុំខ្លួន និងក្នុងករណីជនទេសន្តរប្រវេសន៍មិនប្រក្រតី ការនិរទេស។ ពលករទេសន្តរប្រវេសន៍ ដែលបានចូល និងស្នាក់នៅក្នុងប្រទេសមួយដោយខុសច្បាប់ រមែងតែងត្រូវបានចាប់ខ្លួន ឃុំខ្លួន និងនិរទេសចំពោះបទល្មើសផ្នែកអន្តោប្រវេសន៍ និងចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងពេលនៃការជួញដូរពួកគេ។ ជនទេសន្តរប្រវេសន៍មិនប្រក្រតីរមែងតែងត្រូវចាត់ទុកថាជាជនរងគ្រោះរបស់ជនរត់ពន្ធមនុស្ស ជាជាងជនជួញដូរមនុស្ស ហេតុនេះ ពួកគេមិនត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរឡើយ។ ជាទូទៅ ពួកគេជាច្រើនត្រូវបានបញ្ជូនទៅកាន់មណ្ឌលឃុំឃាំងអន្តោប្រវេសន៍ ពន្ធនាគារ ឬទីកន្លែងបិទជិត ដែលពួកគេគ្មានសេរីភាពក្នុងការចេញចូល។

**គន្លឹះទី ៣៖**
ជនដែលត្រូវគេជួញដូរម្នាក់ អាចមិនមានបំណងឱ្យគេកំណត់អត្តសញ្ញាណខ្លួនថាជាជនរងគ្រោះ ឬមិនមានបំណងទទួលជំនួយ ឬកិច្ចការពារទេ។ ពួកគេគប្បីនៅតែទទួលបានការធានាអះអាងថា ពួកគេនឹងមិនទទួលរងទណ្ឌកម្ម ឬការផ្តន្ទាទោសព្រហ្មទណ្ឌឡើយ។

**គន្លឹះទី ៤៖**
ប្រសិនបើមានមូលហេតុដ៏ល្អក្នុងការជឿថានរណាម្នាក់ត្រូវបានជួញដូរ ជននោះគប្បីត្រូវទទួលបានការប្រព្រឹត្តចំពោះខ្លួនក្នុងនាមជាជនរងគ្រោះ សម្រាប់គោលបំណងនៃការផ្តល់កិច្ចការពារ និងការគាំទ្រដល់ពួកគេរហូតដល់មានការកំណត់ផ្សេងពីនេះ។ ចំណុចនេះមានសារៈសំខាន់ជាពិសេសចំពោះករណីនៃជនទេសន្តរប្រវេសន៍មិនប្រក្រតី និងកុមារ។[5]

**គន្លឹះទី ៥៖**
ធានាថាជនរងគ្រោះដោយអំពើជួញដូរមិនទទួលរងការឃុំខ្លួន ការនិរទេស ការផ្តន្ទាទោស ឬទណ្ឌកម្មចំពោះសកម្មភាពខុសច្បាប់ណាមួយ ដែលពួកគេបានចូលរួមពាក់ព័ន្ធ ដែលជាផលវិបាកនៃស្ថានភាពជាជនដែលត្រូវគេជួញដូររបស់ពួកគេឡើយ រួមទាំងការរំលោភ និងបទល្មើសពាក់ព័ន្ធពេស្យាកម្ម បទលហុ ឬច្បាប់អន្តោប្រវេសន៍។

5 ASEAN Commission on the Promotion and Protection of the Rights of Women and Children. Regional Guidelines and Procedures to Address the Needs of Victims of Trafficking in Persons. Annex: References and Good Practices. (n.d.).

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការប៉ះទង្គិចផ្លូវចិត្តសារជាថ្មីដោយការអនុវត្តច្បាប់នៅក្នុងអំឡុងពេលសម្ភាសន៍

ជាផ្នែកមួយនៃដំណើរការកំណត់អត្តសញ្ញាណ និងជួយជនរងគ្រោះ ជនរងគ្រោះដោយអំពើជួញដូរត្រូវបានសួរសំណួរនានា ឬឱ្យរៀបរាប់ឡើងវិញនូវព័ត៌មានលម្អិតអំពីបទពិសោធន៍នៃការជួញដូររបស់ពួកគេ។ ការធ្វើបែបនេះដាក់បន្ទុកផ្លូវកាយ ផ្លូវចិត្ត និងសង្គមទៅលើបុគ្គល ដែលកំពុងស្ថិតក្រោមភាពតានតឹងក្នុងចិត្តរួចហើយ។ បុគ្គលមួយចំនួនអាចទទួលរងវិបត្តិបាក់ស្បាត និងការបាត់បង់ការចងចាំ ពោលគឺជាការត្អូញត្អែរទូទៅខ្លាំងនៅក្នុងអំពើជួញដូរមនុស្ស ដោយសារជនរងគ្រោះបានទទួលរងការរំលោភបំពាន អំពើហិង្សា ទណ្ឌកម្ម និងការបោកប្រាស់ក្នុងរយៈពេលយ៉ាងវែង និងដែលបានកើតឡើងម្តងហើយម្តងទៀត។[6]

**គន្លឹះទី ៦៖**

ជនរងគ្រោះគប្បីត្រូវបានសម្ភាសដោយនរណាម្នាក់ដែលមានយេនឌ័រដែលពួកគេមានអារម្មណ៍សុខស្រួលជាមួយ។

**គន្លឹះទី ៧៖**

ធ្វើការត្រួតពិនិត្យ ឬការសម្ភាសនៅក្នុងបរិយាកាសមានសុវត្ថិភាព និងកិច្ចការពារ ដែលអនុវត្តដោយនគរបាល/អ្នកស៊ើបអង្កេតអន្តោប្រវេសន៍ អ្នកជំនាញចិត្តសង្គម/វេជ្ជសាស្ត្រ បុគ្គលិកសង្គម ឬដៃគូអង្គការមិនមែនរដ្ឋាភិបាលឯកទេស ដែលទទួលបានការបណ្តុះបណ្តាលពិសេស។[7]

**គន្លឹះទី ៨៖**

ធានាអះអាងចំពោះជនរងគ្រោះអំពីសិទ្ធិរបស់ពួកគេចំពោះឯកជនភាព និងអនាមិកភាព និងប្រាប់ពួកគេអំពីវិធានការដាក់លាក់ដែលត្រូវបានអនុវត្ត ដើម្បីធានាការរក្សាការសម្ងាត់ចំពោះព័ត៌មានដែលពួកគេផ្តល់ឱ្យ។

**គន្លឹះទី ៩៖**

នៅពេលសុំការយល់ព្រម និងការសុខចិត្ត ( សម្រាប់កុមារ និងយុវជន ) ការដាក់សម្ពាធលើជនម្នាក់ ឬសូម្បីតែការនិយាយបង្កប់ន័យអំពីអ្វីដែលល្អបំផុតសម្រាប់ពួកគេ គឺមិនអាចទទួលយកបានឡើយ។ ព័ត៌មាន និងសំណើដែលពាក់ព័ន្ធនឹងការយល់ព្រម ចាំបាច់ត្រូវបង្ហាញក្នុងលក្ខណៈអព្យាក្រិត្យ ដែលបង្ហាញថា បុគ្គលនេះមានសេរីភាពក្នុងការជ្រើសរើស និងថា ជម្រើសអ្វីក៏ដោយរបស់ពួកគេនឹងត្រូវទទួលយកដោយគ្មានការលម្អៀងប្រឆាំងនឹងពួកគេឡើយ។[8]

6 IOM. Caring for Trafficked Persons, Guidance for Health Providers. ( Geneva: 2009 ). https://publications.iom.int/system/files/pdf/ct_handbook.pdf

7 ASEAN. Gender Sensitive Guideline for Handling Women Victims of Trafficking in Persons. ( Jakarta: 2016 ). https://asean.org/ wp-content/uploads/2012/05/ FAASN_gender_8_email_REV. pdf ( Paragraph 3.3.1 )

8 Ibid.

### គន្លឹះទី ១០៖

ពិចារណាផ្តល់ការអនុញ្ញាតឱ្យមានវត្តមានរបស់បុគ្គលផ្តល់ការគាំទ្រ ឬមិត្តភក្តិ នៅក្នុងអំឡុងពេលនៃការសម្ភាស នៅពេលជនរងគ្រោះ ឬសាក្សីស្នើសុំ។

### គន្លឹះទី ១១៖

ប្រើប្រាស់អ្នកបកប្រែដែលទទួលបានការត្រួតពិនិត្យយ៉ាងច្បាស់ពីអាជ្ញាធរពាក់ព័ន្ធ។ មិនគប្បីប្រើប្រាស់នរណាម្នាក់មកពីសហគមន៍របស់បុគ្គលនេះ (រួមមានមិត្តភក្តិ គ្រួសារ អ្នកជិតខាង អ្នកដឹកនាំសហគមន៍ ឬអ្នកមានទំនាក់ទំនងជាមួយមនុស្សដែលអាចជាអ្នកកេងប្រវ័ញ្ច) ឱ្យធ្វើជាអ្នកបកប្រែឡើយ។[9]

### គន្លឹះទី ១២៖

ជៀសវាងសួរសំណួរនានា ដែលបង្ហាញបញ្ជិតបញ្ជៀងអំពីការវិនិច្ឆ័យអវិជ្ជមានចំពោះសេចក្តីសម្រេចចិត្តរបស់ជនរងគ្រោះ សកម្មភាពរបស់ពួកគេ ឬសួរអំពីចរិតលក្ខណៈរបស់ពួកគេឡើយ។ គប្បីសួរសំណួរនានាក្នុងលក្ខណៈផ្តល់ការគាំទ្រ គ្មានការវិនិច្ឆ័យ និងគប្បីបញ្ជាក់ការឆ្លើយតបរបស់ជនរងគ្រោះក្នុងលក្ខណៈផ្តល់ការគាំទ្រ។[10]

### គន្លឹះទី ១៣៖

រក្សាគម្លាត និងអត្តចរិតវិជ្ជាជីវៈ ប៉ុន្តែក្នុងពេលជាមួយគ្នា ត្រូវមានភាពអាណិតអាសូរ និងការជួយសម្រាលទុក្ខ។[11] ធានាអះអាងចំពោះជនរងគ្រោះថា ពួកគេមិនមែនជាអ្នកដែលត្រូវទទួលរងការស្តីបន្ទោសឡើយ និងពន្យល់ថា អ្វីដែលបានកើតឡើងចំពោះពួកគេ មិនមែនជាកំហុសរបស់ពួកគេឡើយ។ ចាំបាច់ត្រូវពន្យល់ជនរងគ្រោះថា ពួកគេគ្មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬសីលធម៌ចំពោះការចាញ់ល្បិចកល ឬការទទួលរងការបង្ខិតបង្ខំឱ្យពាក់ព័ន្ធក្នុងការធ្វើដំណើរនេះ ឬការចូលរួមនៅក្នុងសកម្មភាពជាបន្តបន្ទាប់ដែលបានកើតឡើងឡើយ។[12]

### គន្លឹះទី ១៤៖

ប្រសិនបើបុគ្គលម្នាក់បង្ហាញសញ្ញានៃភាពអន្ទះអន្ទែង ឬការថប់បារម្ភធ្ងន់ធ្ងរ គប្បីផ្អាក ឬបញ្ឈប់ការសម្ភាស រហូតដល់ពេលអាចបន្តទៅមុខទៀតបាន។ នៅក្នុងអំឡុងពេលនៃការសម្ភាស ចាំបាច់ត្រូវពិនិត្យមើលទម្រង់នៃទំនាក់ទំនងដែលមិនបង្ហាញតាមរយៈពាក្យសម្តី ដូចជា សញ្ញានានានៃការភ័យខ្លាច ឬការថប់បារម្ភ ឬការអស់កម្លាំងខ្លាំង។ នៅពេលណាដែលមានមូលហេតុក្នុងការជឿថាបុគ្គលដែលកំពុងត្រូវសម្ភាស កំពុងទទួលរងការប៉ះទង្គិចផ្លូវចិត្តខ្លាំង គប្បីស្វែងរកជំនួយពីអ្នកចិត្តសាស្រ្ត មុនពេលបន្តទៅមុខទៀត។[13]

9 Bali Process. Policy Guide on Identifying Victims of Trafficking: An Introductory Guide for Policy Makers and Practitioners. (Bangkok, Regional Support Office of the Bali Process: 2015). https:// www. baliprocess.net/UserFiles/ baliprocess/File/ Policy%20 Guide%20on%20Identifying%20 VIctims%20of%20Trafficking.pdf

10 OSCE. Questioning victims of trafficking: The P.E.A.C.E. Model. (Uzbekistan: 2016). https://polis. osce.org/index.php/ questioningvictims-trafficking-peace-model

11 IOM. The IOM Handbook on Direct Assistance for Victims of Trafficking. (Geneva: 2007). https://publications.iom.int/ system/files/pdf/iom_handbook_assistance. pdf

12 IOM (2007)

13 IOM (2007)

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការមិនផ្តល់ភាពអង់អាច ការកំណត់អត្តសញ្ញាណដោយបង្ខំ និងជំនួយដោយបង្ខំ

មិនមែនជនត្រូវជួញដូរទាំងអស់សុទ្ធតែមើលខ្លួនឯងថាជាជនរងគ្រោះឡើយ។ ជនរងគ្រោះមួយចំនួនអាចមិនមានបំណងឱ្យមានការកំណត់អត្តសញ្ញាណឡើយ និងព្យាយាមជៀសវាង ឬគេចវេសពីការកំណត់អត្តសញ្ញាណ។[14] សម្រាប់ជនដែលត្រូវគេជួញដូរខ្លះ ដំណើរការកំណត់អត្តសញ្ញាណផ្លូវការមានទំនាក់ទំនងជាមួយនឹងជំនួយ ដែលពួកគេមិនចង់បាន ឬក្នុងទម្រង់ដែលពួកគេមិនចង់ទទួល (ឧទាហរណ៍ដោយសារជំនួយនោះតម្រូវឱ្យមានការស្នាក់នៅក្នុងមណ្ឌលឬការរស់នៅបែកពីគ្រួសាររបស់ពួកគេ)។ការកំណត់អត្តសញ្ញាណក៏អាចតម្រូវឱ្យពួកគេវិលត្រឡប់ទៅប្រទេសដើម ឬកន្លែងដើមរបស់ពួកគេផងដែរ ដែលពួកគេអាចមានបំណងជៀសវាង ដោយសារសង្ឃឹមថា ពួកគេនឹងស្វែងរកការងារធ្វើនៅក្នុងប្រទេស ឬទីក្រុងគោលដៅវិញ។

**គន្លឹះទី ១៥៖**

ផ្តល់ព័ត៌មានពេញលេញដល់ជនរងគ្រោះអំពីគោលបំណងនៃការប្រមូលទិន្នន័យ និងរបៀបនៃការប្រើប្រាស់ទិន្នន័យទាំងនោះ។ ពួកគេគប្បីដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការចូលរួម និងសិទ្ធិបញ្ចប់ការសម្ភាសនេះ ទោះជានៅពេលណាក៏បាន។

**គន្លឹះទី ១៦៖**

ធានាថា ជនរងគ្រោះដោយអំពើជួញដូរដែលត្រូវបានកំណត់អត្តសញ្ញាណទទួលបានព័ត៌មានច្បាស់លាស់អំពីប្រភេទនៃកិច្ចការពារ ជំនួយ និងការគាំទ្រ ដែលពួកគេមានសិទ្ធិទទួលបាននៅក្រោមច្បាប់របស់ប្រទេស និងអនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (ACTIP) នៅក្នុងរយៈពេលសមស្របមួយ។[15]

**គន្លឹះទី ១៧៖**

ជនរងគ្រោះគប្បីត្រូវបានផ្តល់ជូននូវរយៈពេលសម្រាប់ការឆ្លុះបញ្ចាំង និងការធូរស្បើយឡើងវិញ ដែលនៅក្នុងពេលនោះ ការគាំទ្រដោយគ្មានលក្ខខណ្ឌ (រួមមាន មណ្ឌលស្នាក់នៅ ការព្យាបាលវេជ្ជសាស្ត្រ ជំនួយផ្លូវច្បាប់ ការផ្តល់ប្រឹក្សា ទំនាក់ទំនងជាមួយគ្រួសាររបស់ពួកគេ។ល។) ត្រូវបានផ្តល់ឱ្យពួកគេ ជាមួយនឹងគោលបំណងនៃការផ្តល់ដល់ពួកគេនូវពេលវេលា និងលំហ ដើម្បីធ្វើសេចក្តីសម្រេចចិត្តអំពីជម្រើសនានារបស់ពួកគេ រួមទាំងតើពួកគេនឹងសហការជាមួយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌនៅក្នុងការផ្តន្ទាទោសជនកេងប្រវ័ញ្ចពួកគេដែរ ឬទេ។[16]

14 IOM (2007)

15 អនុសញ្ញា ACTIP មាត្រា ១៤(៩)

16 Bali Process (2015)

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការរើសអើង ការមាក់ងាយ និងការបដិសេធពីគ្រួសារ និងសហគមន៍

ជនរងគ្រោះអាចជួបប្រទះការរើសអើងរួចហើយ ដោយសារសញ្ជាតិ ជាតិពន្ធុ សាសនា យេនឌ័រ អាយុ ឬកត្តាផ្លូវភេទរបស់ពួកគេ។ ជនទាំងឡាយដែលត្រូវបានកេងប្រវ័ញ្ចទៅក្នុងការងារផ្លូវភេទ អាចមានអារម្មណ៍អាម៉ាស់ និងស្ទាក់ស្ទើរក្នុងចែករំលែកអំពីរឿងរ៉ាវរបស់ពួកគេ ដោយសារភ័យខ្លាចចំពោះការរើសអើង ការមាក់ងាយ និងការបដិសេធបន្ថែមទៀតពីគ្រួសារ និងសហគមន៍។[17] នៅក្នុងករណីនានា ដែលការអនុវត្តបែបវប្បធម៌ ទំនៀមទម្លាប់ និងសាសនា ចាត់ទុកអំពើហិង្សា និងការកេងប្រវ័ញ្ច គឺជារឿងធម្មតាដូចជា អាពាហ៍ពិពាហ៍ក្នុងវ័យកុមារ អាពាហ៍ពិពាហ៍ដោយបង្ខំ ឬអាពាហ៍ពិពាហ៍បណ្តោះអាសន្ន ជនរងគ្រោះមិនទំនងជាចេញមុខឡើយ និងអាចគិតថា ពួកគេមិនអាចទទួលបានឧបាស្រ័យចំពោះភាពយុត្តិធម៌ឡើយ។[18]

**គន្លឹះទី ១៨៖**

កិច្ចដំណើរការកំណត់អត្តសញ្ញាណត្រូវតែមានលក្ខណៈបរិយាប័ន្ន និងអនុញ្ញាតឱ្យជនរងគ្រោះដោយអំពើជួញដូរទាំងអស់ទទួលបានការកំណត់អត្តសញ្ញាណ រួមមាន ស្ត្រី និងកុមារី និងបុរស និងកុមារា។ អ្នកឆ្លើយតបជួរមុខ និងអ្នកផ្តល់ការគាំទ្រគួរតែដឹងពីភាពលំអៀងរបស់ពួកគេ និងចៀសវាងនូវអាកប្បកិរិយាជាពាក្យសំដី ឬមិនមែនជាពាក្យសំដីណាមួយ ដែលធ្វើបុគ្គលកំពុងត្រូវសម្ភាស មានអារម្មណ៍មិនល្អ។[19] អ្នកឆ្លើយតបជួរមុខ ឬអ្នកផ្តល់ការគាំទ្រគប្បីធ្វើស្វ័យប៉ាន់ប្រមាណថា តើពួកគេមានការគិតទុកជាមុនបែបអវិជ្ជមាន ការរើសអើង ភាពលម្អៀង ឬអារម្មណ៍ប្រកាន់ពូជសាសន៍ណាមួយចំពោះជនរងគ្រោះដែរ ឬទេ។[20] ពួកគេត្រូវតែពិចារណាទៅលើអារម្មណ៍របស់ពួកគេចំពោះបុគ្គល ដែលបានពាក់ព័ន្ធនៅក្នុងប្រភេទទូទៅនៃការជួញដូរកម្លាំងពលកម្ម (ឧទា. ការងារផ្លូវភេទ ការសុំទាន ការងារតាមផ្ទះ) បុគ្គលដែលជាជនរងគ្រោះដាក់លាក់នៃការរំលោភបំពាន (ឧទា. ការរំលោភបំពានផ្លូវភេទ) បុគ្គលដែលអាចទទួលរងការមាក់ងាយ ឬជំងឺ ឬរបួសដែលអាចមើលឃើញបាន (ឧទា. ជនផ្ទុកមេរោគអេដស៍ រាងកាយមិនធម្មតា ឬពិការភាព) ជនទេសន្តរប្រវេសន៍ អ្នកប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង បុគ្គលដែលកំណត់ខ្លួនឯងថាជាអ្នកស្រឡាញ់ភេទដូចគ្នា និងបុគ្គលដែលមានជំនឿ ឬការអនុវត្តផ្នែកសង្គម វប្បធម៌ ឬសាសនា ខុសពីជំនឿ ឬការអនុវត្តរបស់ពួកគេ។

17 Inter-Agency Coordination Group against Trafficking in Persons (ICAT). Draft Submission to CEDAW's General Recommendation on Trafficking in Women and Girls in the Context of Global Migration (n.d.) http://icat.network/sites/default/files/publications/documents/ICAT%20submission%20to%20CEDAW.pdf

18 UNODC. Toolkit for mainstreaming human rights and gender equality into criminal justice interventions to address trafficking in persons and smuggling of migrants. (UNODC & IOM, Vienna: 2021) https://www.unodc.org/documents/human-trafficking/GLO-ACTII/UNODC_Toolkit_for_mainstreaming_Human_Rights_and_Gender_Equality_February_2021.pdf

19 កែសម្រួលពី IOM, "Victim identification and interview technique" (2006)

20 IOM (2007).

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ កង្វះលទ្ធភាពទទួលបានកិច្ចការពារ និងកន្លែងស្នាក់នៅដែលមានសុវត្ថិភាព

ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ អាចភ័យខ្លាចអំពីជីវិត និងសុវត្ថិភាពរបស់ពួកគេ។ ការជួបប្រទះនឹងបទពិសោធន៍ប៉ះទង្គិចផ្លូវចិត្តយ៉ាងយូរ និងម្តងហើយម្តងទៀតរបស់ពួកគេ រួមមានការរំលោភបំពាន និងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ការបង្អត់ និងទណ្ឌកម្ម។ មណ្ឌលស្នាក់នៅ ឬកន្លែងស្នាក់នៅបណ្តោះអាសន្នដែលមានសុវត្ថិភាព និងសន្តិសុខ រមែងតែងជាវិធីមួយ សម្រាប់ ជនរងគ្រោះដោយអំពើជួញដូរទទួលបានសេវាចាំបាច់នានា រួមមាន ជំនួយវេជ្ជសាស្ត្រ និង ដើម្បីធូរស្បើយឡើងវិញពីបទពិសោធន៍នៃអំពើជួញដូររបស់ពួកគេ។ ថ្វីបើបែបនេះក្តី ការទទួលបានកិច្ចការពារ និងមណ្ឌលស្នាក់នៅ និងកន្លែងស្នាក់នៅសមស្រប គឺជាបញ្ហាប្រឈមមួយនៅក្នុងប្រទេសជាច្រើន។[21]

**គន្លឹះទី ១៩៖**

ធ្វើការផ្ទេរអ្នកទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនរងគ្រោះដោយអំពើជួញដូរជាបន្ទាន់ទៅកាន់មណ្ឌលស្នាក់នៅ ឬកន្លែងស្នាក់នៅបណ្តោះអាសន្ន ដែលមានសុវត្ថិភាព និងសន្តិសុខ។ ពួកគេក៏គប្បីត្រូវបានបញ្ជូនយ៉ាងឆាប់រហ័សទៅកាន់ស្ថាប័នទទួលខុសត្រូវដើម្បីទទួលបានជំនួយ និងការគាំទ្រឯកទេស។[22]

**គន្លឹះទី ២០៖**

សម្រាប់ស្ត្រីរងគ្រោះដោយអំពើជួញដូរ ដែលអាចធ្លាប់ជួបប្រទះនឹងអំពើហិង្សាផ្លូវកាយ និងផ្លូវភេទ ធានាថា មានឱកាសមួយសម្រាប់ការបញ្ជូនពួកគេទៅរកសេវាឯកទេសផ្នែកអំពើហិង្សាលើស្ត្រី។

**គន្លឹះទី ២១៖**

ស្ត្រីមានផ្ទៃពោះ និងស្ត្រីកំពុងបំបៅដោះកូន និងស្ត្រីជាម្តាយដែលមានកូនតូចមកជាមួយ គប្បីត្រូវបានផ្តល់ទីកន្លែងសមស្របនិងដោយឡែក។[23]

**គន្លឹះទី ២២៖**

នៅពេលអាចធ្វើបាន ផ្តល់ជូនជនរងគ្រោះនូវជម្រើសក្នុងការទទួលការថែទាំនៅក្រៅប្រព័ន្ធមណ្ឌលស្នាក់នៅផ្លូវការ។ កន្លែងស្នាក់នៅនេះអាចជាកន្លែងស្នាក់ដែលមានសុវត្ថិភាព និងសមស្រប រួមមាន ផ្ទះជួល បន្ទប់ជួល ឬ ផ្ទះនៅតាមសហគមន៍។[24]

21 Anti-Slavery International (2002).

22 គោលការណ៍ណែនាំអាស៊ានពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ចំពោះយេនឌ័រ កថាខណ្ឌ ៣.៣.១

23 UNICEF, UNODC, UN Women. The role of law enforcement to protect women and children during a public health crisis, including COVID-19. See https:// asiapacific.unwomen.org/-/ media/field%20office%20eseasia/ docs/misc/2020/09/poster_%20law%20enforcement%20 women%20and%20girls%20 covid%2019_%20burmese. pdf?la=en&vs=5708

24 McAdam, M. Freedom of movement for victims of trafficking: Law, policy and practice in the ASEAN region. Information note supported by the Australian Government. (Bangkok, 2020). https://aseanactpartnershiphub.com/resources/asean-shelter-study-mcadam-freedom-of-movement-for-victims-of-trafficking-final/

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការវិលត្រឡប់ដោយបង្ខំទៅកាន់ប្រទេស/កន្លែងដើមវិញ

ការបញ្ជូនជនរងគ្រោះត្រឡប់ទៅកាន់កន្លែងដើមវិញ មានហានិភ័យនក្នុងការធ្វើឱ្យពួកគេធ្លាក់ទៅក្នុងស្ថានភាពដូចមុនពេលដែលត្រូវបានគេជួញដូរ ជាញឹកញាប់ដោយមានប្រាក់ចំណូលមានកម្រិតឬគ្មានប្រាក់ចំណូល ឬលទ្ធភាពទទួលបានការគាំទ្រមានកម្រិត។[25] ពួកគេអាចទទួលរងអំពើហិង្សា និងការបំភិតបំភ័យពីសំណាក់ជនជួញដូរ ជាពិសេស ប្រសិនបើពួកគេបានសហការជាមួយស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ ឬជំពាក់ប្រាក់ដែលមិនអាចសងវិញបាន។[26]

**គន្លឹះទី ២៣៖**

ធានាថា ជនរងគ្រោះ ដែលមានបំណងបន្តនៅក្នុងប្រទេសនេះ មានលទ្ធភាពទទួលបានការពិគ្រោះយោបល់ផ្នែកច្បាប់ដោយឯករាជ្យដើម្បីធានានូវការវិលត្រឡប់ដោយសុវត្ថិភាព ឬដោយស្ម័គ្រចិត្ត។[27] ដើម្បីគោរពសិទ្ធិរបស់ជនដែលត្រូវគេជួញដូរ ស្ថាប័ននានាត្រូវតែធានាថា ការវិលត្រឡប់របស់ជនរងគ្រោះត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត និងដោយផ្អែកលើការយល់ព្រមប្រកបដោយព័ត៌មានគ្រប់គ្រាន់ និងនៅពេលអាចធ្វើបាន ការយល់ព្រមបែបនេះជាលាយលក្ខណ៍អក្សរពីជនរងគ្រោះ។[28] ត្រូវផ្តល់ការអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្នដោយឈរលើមូលដ្ឋានសង្គម ឬមនុស្សធម៌ ដែលអាចទាក់ទងជាមួយនឹង ឧទាហរណ៍ ការគោរពចំពោះគោលការណ៍នៃការមិនបញ្ជូនត្រឡប់ទៅកាន់កន្លែងដែលប្រឈមនឹងគ្រោះថ្នាក់ អសមត្ថភាពក្នុងការធានានូវការវិលត្រឡប់ដោយសុវត្ថិភាព និងហានិភ័យនៃការជួញដូរសារជាថ្មី។

25 UNODC (2009).

26 ASEAN. Regional Review on Laws, Policies and Practices within ASEAN relating to the Identification, Management and Treatment of Victims of Trafficking, especially Women and Children. (Jakarta: 2016); https://asean.org/?static_post=asean-handbook-on-international-legal-cooperation-in-trafficking-in-persons-cases-3

27 ការពិនិត្យឡើងវិញថ្នាក់តំបន់របស់អាស៊ាន (ឆ្នាំ២០១៦) អនុសាសន៍ ៧.២

28 ពិធីសារអង្គការសហប្រជាជាតិស្តីពីការប្រឆាំងការជួញដូរមនុស្ស មាត្រា ៨។

## ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ៖ ការបង្កគ្រោះថ្នាក់ដែលអាចកើតឡើង និងគន្លឹះសម្រាប់ការមិនបង្កគ្រោះថ្នាក់

សិទ្ធិ និងតម្រូវការរបស់ជនរងគ្រោះ គឺជាស្នូលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល។ ទោះបីជាយ៉ាងណាក្តី ពួកគេរមែងតែងចាត់ទុកថាជាចំណែកមួយនៃភ័ស្តុតាងនៅក្នុងកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ ដែលផ្តោតលើការផ្តន្ទាទោសជនល្មើស។ គោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់របស់អាស៊ាន បញ្ជាក់ថា*ជនរងគ្រោះដោយអំពើជួញដូរទាំងអស់ ដែលចូលរួមនៅក្នុងការស៊ើបអង្កេត ឬការផ្តន្ទាទោសជនកេងប្រវ័ញ្ចពួកគេ គប្បីទទួលបានកិច្ចការពារ ការគាំទ្រ និងជំនួយគ្រប់គ្រាន់ ដែលកំណត់ដោយច្បាប់ នៅក្នុងរយៈពេលនៃការចូលរួមរបស់ពួកគេនៅក្នុងកិច្ចដំណើរការព្រហ្មទណ្ឌ។* បណ្តាប្រទេសអាស៊ានត្រូវបានតម្រូវឱ្យធានាថាជនរងគ្រោះដឹងអំពីសំណងឧបាស្រ័យដែលមាន និងរៀបចំច្បាប់ និងនីតិវិធីចាំបាច់នានាដើម្បីធានានូវលទ្ធភាពទទួលបានសំណង។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ អវត្តមាននៃការយល់ព្រមប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយ

ការទទួលបានការយល់ព្រម ដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយពីជនរងគ្រោះដោយអំពើជួញដូរ គឺជាការពិបាក។ ដំបូង ភាពខុសគ្នាផ្នែកភាសា វប្បធម៌ សេដ្ឋកិច្ចសង្គម គឺជាឧបសគ្គចម្បង។ បន្ថែមលើនេះ ជនរងគ្រោះមួយចំនួនទទួលបានការសន្យាអំពីការគាំទ្រហិរញ្ញវត្ថុ កិច្ចការពារ សំណង ការស្នាក់នៅក្នុងមណ្ឌលរយៈពេលខ្លី ឬអ្វីផ្សេងទៀត ដើម្បីទទួលកិច្ចសហការរបស់ពួកគេនៅក្នុងកិច្ចដំណើរការផ្លូវច្បាប់។

### គន្លឹះទី ១៖

ស្នើសុំការយល់ព្រមដោយស្ម័គ្រចិត្ត និងប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់ការចូលរួមនៅក្នុងដំណើរការនេះ និងអនុញ្ញាតឱ្យជនរងគ្រោះបដិសេធចំពោះជំនួយ និងកិច្ចការពារនៅពេលណាមួយក៏បាននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌនេះ។

### គន្លឹះទី ២៖

ប្រាប់ដល់ជនរងគ្រោះនៅមុនពេល និងក្នុងអំឡុងពេលនៃការចូលរួមរបស់ពួកគេនៅក្នុងកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌអំពីប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ តួនាទីផ្លូវច្បាប់របស់ពួកគេ សិទ្ធិរបស់ពួកគេ ជម្រើសរបស់ពួកគេ សេវាដែលមាន និងកត្តាពេលវេលានៅក្នុងដំណើរការជំនុំជម្រះដោយប្រើប្រាស់សំនៀងលក្ខណៈមិនគំរាមកំហែង និងជាភាសាដែលពួកគេយល់។ គប្បីពិចារណាជាអាទិ៍លើសញ្ជាតិ ជាតិពន្ធុ អាយុ ពិការភាព កត្តាផ្លូវភេទរបស់ពួកគេ។[29]

### គន្លឹះទី ៣៖

ផ្តល់ពេលវេលាសម្រាប់ការឆ្លុះបញ្ចាំង និងការធូរស្បើយឡើងវិញ សម្រាប់ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ ដើម្បីធ្វើសេចក្តីសម្រេចចិត្តប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយអំពីការសហការ និងជួយឱ្យជនរងគ្រោះជៀសវាងការយល់ព្រម "ដោះស្រាយ" ក្រៅផ្លូវការចំពោះករណីរបស់ពួកគេ ដើម្បីពួកគេវិលត្រឡប់ទៅរកជីវិតជាធម្មតាវិញ។ ការរៀបចំក្រៅផ្លូវការបែបនេះ គឺជៀសមិនផុតពីការសម្របសម្រួល ជាពិសេសវាជាការលើកទឹកចិត្តចំពោះអំពើពុករលួយ និងធ្វើឱ្យមាននិទណ្ឌភាពសម្រាប់ជនកេងប្រវ័ញ្ច។[30]

29 ផែនការសកម្មភាពអាស៊ានប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ ផ្នែក ខ (ឆ) គោលការណ៍ណែនាំអាស៊ានស្តីពីការយកចិត្តទុកដាក់ចំពោះយេនឌ័រ កថាខណ្ឌ ៣.៦.៤ ការពិនិត្យឡើងវិញថ្នាក់តំបន់របស់ ACWC អនុសាសន៍ ៤.៤។

30 ASEAN. Practitioners' Model Implementation Toolkit for the ACWC Regional Guidelines and Procedures to Address the Needs of Victims of Trafficking in Persons (2019).

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ត្រូវបានបំភិតបំភ័យ ឬត្រូវបានបង្ខំឱ្យផ្តល់សក្ខីកម្មប្រឆាំងនឹងជនកេងប្រវ័ញ្ចពួកគេ

ជនរងគ្រោះដោយអំពើជួញដូរជាច្រើន មើលមិនឃើញអត្ថប្រយោជន៍ជាក់ស្តែងពីការចូលរួមនៅក្នុងកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌឡើយ ប៉ុន្តែអាចទទួលរងការបំភិតបំភ័យ ឬការកៀបសង្កត់ឱ្យចូលរួមពីសំណាក់មន្ត្រី ព្រះរាជអាជ្ញា មេធាវី ឬអ្នកផ្តល់សេវាដទៃទៀតដែលពាក់ព័ន្ធ។ ការភ័យខ្លាចរបស់ពួកគេអំពីការបង្ខំឱ្យវិលត្រឡប់ទៅផ្ទះវិញ ដើម្បីប្រឈមមុខនឹងការមាក់ងាយ និងការបដិសេធពីសំណាក់គ្រួសារ និងសហគមន៍របស់ពួកគេ អាចបង្កឱ្យមានភាពអស់ទឹកចិត្ត។

**គន្លឹះទី ៤៖**
សម្រេចចិត្តរួមគ្នាជាមួយជនរងគ្រោះ ថាតើជម្រើសដទៃទៀត ដូចជាភស្តុតាងបញ្ជាក់បន្ថែម និងសាក្សីជំនាញ/សាក្សីដទៃទៀត អាចត្រូវបានយកមកប្រើប្រាស់ជំនួសឱ្យការដែលតម្រូវឱ្យជនរងគ្រោះត្រូវផ្តល់ចម្លើយ និងសក្ខីកម្ម ប្រសិនបើការដែលតម្រូវឱ្យជនរងគ្រោះត្រូវផ្តល់ចម្លើយ ឬសក្ខីកម្មដោយផ្ទាល់ អាចបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះ។ ការប្រើប្រាស់ភស្តុតាងបញ្ជាក់បន្ថែមក៏មានន័យថា ករណីនេះមិនពឹងផ្អែកទាំងស្រុងតែទៅលើសក្ខីកម្មរបស់ជនរងគ្រោះ និងអាចបន្តទៅមុខបានប្រសិនបើជនរងគ្រោះមិនអាច ឬមិនមានបំណងផ្តល់សក្ខីកម្ម។

**គន្លឹះទី ៥៖**
ជៀសវាងការប្រព្រឹត្តចំពោះជនរងគ្រោះដោយអំពើជួញដូរថាជាប្រភពនៃភស្តុតាងសុទ្ធសាធ។ នេះគឺជាអភិក្រមរយៈពេលខ្លី ដែលទំនងជាបរាជ័យ។ ជនរងគ្រោះ និងសាក្សីកាន់តែទំនងជាសហការនៅក្នុងការស៊ើបអង្កេត និងកិច្ចដំណើរការផ្តន្ទាទោស ប្រសិនបើពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងមានសន្តិសុខ ហើយតម្រូវការរបស់ពួកគេត្រូវបានគេយល់ និងឆ្លើយតបយ៉ាងសមស្រប។[31]

**គន្លឹះទី ៦៖**
ប្រាប់ជនរងគ្រោះថា ពួកគេមានសិទ្ធិមានវត្តមាន និងបង្ហាញទស្សនៈរបស់ពួកគេនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការផ្លូវច្បាប់។[32]

31 Office of the High Commissioner for Human Rights. Recommended Principles and Guidelines on Human Rights and Human Trafficking. (n.d.) https://www.ohchr.org/Documents/Publications/Traffickingen.pdf

32 APA Section B(g). UN TIP Protocol, Article 6(2)(b).

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការបាត់បង់ឯកជនភាព និងអនាមិកភាព

ការចូលរួមជាផ្នែកមួយនៃកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ បង្កើនហានិភ័យនៃការរំលោភលើឯកជនភាព និងអនាមិកភាពរបស់ជនរងគ្រោះ។ ការបាត់បង់ឯកជនភាព និងអនាមិកភាពរបស់ពួកគេនឹងមានផលប៉ះពាល់លើសុវត្ថិភាពរបស់ពួកគេ ដោយសារហានិភ័យនៃការសងសឹកពីជនជួញដូរពួកគេ។ វាអាចនាំឱ្យមានភាពអាម៉ាស់ ការបដិសេធ និងទណ្ឌកម្មពីគ្រួសារ ឬសហគមន៍។

**គន្លឹះទី ៧៖**
ប្រសិនបើជនរងគ្រោះសម្រេចចិត្តចូលរួមនៅក្នុងការផ្តន្ទាទោសជនជួញដូរពួកគេ ត្រូវការពារឯកជនភាព និងការរក្សាការសម្ងាត់របស់ពួកគេនៅក្នុងទូទាំងដំណើរការនេះ ឧទាហរណ៍តាមរយៈការមិនចែករំលែកព័ត៌មានលម្អិតដោយគ្មានការអនុញ្ញាតពីពួកគេ ហើយត្រូវរក្សាការសម្ងាត់យ៉ាងតឹងរ៉ឹងចំពោះព័ត៌មានដែលបង្ហាញអត្តសញ្ញាណ ឬអាសយដ្ឋានរបស់ជនរងគ្រោះ។[33]

**គន្លឹះទី ៨៖**
ប្រើប្រាស់វិធានការការពារនៅក្នុងតុលាការ ដូចជា បន្ទប់រង់ចាំដោយឡែក ច្រកចូលឯកជន ការថតសម្លេងនៃការផ្តល់សក្ខីកម្ម ការប្រើប្រាស់ឈ្មោះក្លែងក្លាយ សវនាការបិទទ្វារ ការកែវីដេអូ/សម្លេង កញ្ចក់មើលឃើញតែម្ខាង របាំង ឬវាំងនន ដើម្បីធានានូវអនាមិកភាពរបស់ជនរងគ្រោះ។ ត្រូវពន្យល់ដល់ជនរងគ្រោះផងដែរអំពីរបៀបនៃការផ្តល់សក្ខីកម្មរបស់ពួកគេ និងកម្រិតនៃការបង្ហាញអត្តសញ្ញាណរបស់ពួកគេ (ប្រសិនបើត្រូវធ្វើ) ទៅដល់អ្នកការពារចុងចោទ និងសាធារណៈជន។ ផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ជនរងគ្រោះផ្តល់សក្ខីកម្ម និងសូមកុំនិយាយកាត់ ឬសុំឱ្យពួកគេនិយាយឱ្យលឿននូវការចងចាំអំពីអ្វីដែលបានកើតឡើង។

**គន្លឹះទី ៩៖**
គប្បីតម្រូវឱ្យប្រព័ន្ធផ្សព្វផ្សាយគោរពឯកជនភាព និងការរក្សាការសម្ងាត់របស់ជនរងគ្រោះនិងសាក្សីពាក់ព័ន្ធ ដោយធានាឱ្យបានថាអត្តសញ្ញាណរបស់ពួកគេត្រូវបានការពារក្នុងអំឡុងពេលដំណើរការនីតិវិធីតុលាការ ក៏ដូចជានៅក្រៅបន្ទប់តុលាការ។

33 ដូចមានចែងនៅក្នុងគោលការណ៍អាស៊ានសម្រាប់អ្នកអនុវត្តការងារ៖ "ជនរងគ្រោះ-សាក្សី និងគ្រួសាររបស់ពួកគេ (នៅពេលចាំបាច់) គប្បីទទួលកិច្ចការពារពីការសងសឹក។ ច្បាប់គប្បីត្រូវបានរៀបចំឡើង ដើម្បីការពារឯកជនភាពរបស់ជនរងគ្រោះ-សាក្សី និងរក្សាការសម្ងាត់ចំពោះអត្តសញ្ញាណរបស់ពួកគេ" ផ្នែកទីមួយ ង១ និង ង២ អនុសញ្ញា ACTIP មាត្រា១៤(៦)។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការសងសឹកពីជនជួញដូរ

ការភ័យខ្លាចអំពីការសងសឹកពីជនជួញដូរពួកគេ គឺជាកង្វល់ដ៏ត្រឹមត្រូវ ជាពិសេស សម្រាប់ជនរងគ្រោះ-សាក្សី និងអ្នកទាំងឡាយដែលចូលរួមពាក់ព័ន្ធនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។ សមត្ថភាពរបស់ជនជួញដូរក្នុងការសងសឹកលើជនរងគ្រោះដែលបានគេចខ្លួនរួច និង/ឬបានផ្តល់សក្ខីកម្មប្រឆាំងនឹងពួកគេ ត្រូវបានចងក្រងជាឯកសារយ៉ាងល្អ។[34] បន្ថែមលើនេះ ការសងសឹកក៏អាចមិនត្រឹមតែកើតឡើងពីជនជួញដូរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីនិយោជក ភ្នាក់ងារជួញដូរមនុស្ស មេបន និងមន្ត្រីអនុវត្តច្បាប់ទៀតផង។

**គន្លឹះទី ១០៖**
ត្រូវប៉ាន់ប្រមាណហានិភ័យនៃជនរងគ្រោះដែលត្រូវរងអន្តរាយដោយការចូលរួមក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដោសម្របសម្រួលជាមួយសមត្ថកិច្ចអនុវត្តច្បាប់ និងអ្នកផ្តល់សេវាគាំទ្រជនរងគ្រោះ រួមទាំងអ្នកចិត្តសាស្ត្រ។ ការបកស្រាយហានិភ័យ និងការប៉ាន់ប្រមាណហានិភ័យដោយជនរងគ្រោះ គឺសំខាន់ក្រៃលែងនៅទីនេះ។ ហានិភ័យទាំងនេះ អាចរួមមាន ជាអាទិ៍ ការប៉ះទង្គិចផ្លូវចិត្ត ការសងសឹកពីជនជួញដូរឬបក្សពួក ការមាក់ងាយ និងការធ្វើឱ្យអាប់កិត្តិយសដោយគ្រួសារ ឬសមាជិកសហគមន៍។[35]

**គន្លឹះទី ១១៖**
ប្រសិនបើអាច និងដោយពិគ្រោះយោបល់ជាមួយជនរងគ្រោះ ចាត់តាំងអ្នកស៊ើបអង្កេតជាស្ត្រី និងបុរស ដែលទទួលបានការបណ្តុះបណ្តាលដើម្បីផ្តល់កិច្ចការពារផ្លូវកាយដល់ជនរងគ្រោះ ដែលបង្ហាញការភ័យខ្លាចអំពីជីវិត និងសុវត្ថិភាពរបស់ពួកគេ និងរបស់សមាជិកគ្រួសាររបស់ពួកគេ។ ការផ្តល់សេវាការពារអាចត្រូវបានសម្របសម្រួលជាមួយនឹងស្ថាប័ន /អ្នកសម្របសម្រួលកិច្ចការពារជនរងគ្រោះ និងសាក្សីដែលមាននៅក្នុងដែនសមត្ថកិច្ចមួយចំនួន។

**គន្លឹះទី ១២៖**
ត្រូវបន្តផ្តល់ព័ត៌មានដល់ជនរងគ្រោះអំពីវឌ្ឍនភាពនៃករណីណាមួយដែលពួកគេចូលរួម ហើយពួកគេអាចស្នើសុំព័ត៌មាននៅពេលណាក៏បាន។[36]

34 IOM (2007).

35 កញ្ចប់ឧបករណ៍អាស៊ានស្តីពីគំរូសម្រាប់ការអនុវត្តរបស់អ្នកអនុវត្តការងារ (ឆ្នាំ២០១៩)។

36 APA Section B(g). UN TIP Protocol, Article 6(2)(b).

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការឃុំខ្លួនដោយបង្ខំនៅកន្លែងឃុំឃាំង ឬមណ្ឌលស្នាក់នៅបិទទ្វារ

ជនរងគ្រោះអាចត្រូវបានដាក់នៅក្នុងមណ្ឌលស្នាក់នៅបិទទ្វារ ផ្ទុយពីបំណងរបស់ពួកគេ ដើម្បីការពារសុវត្ថិភាពរបស់ពួកគេ។ នៅប្រទេសមួយចំនួន ជនរងគ្រោះដោយអំពើជួញដូរ ដែលជាជនទេសន្តរប្រវេសន៍មិនប្រក្រតី ត្រូវបានដាក់នៅក្នុងមណ្ឌលស្នាក់នៅរបស់រដ្ឋាភិបាល ឬមណ្ឌលស្នាក់នៅដែលបានទទួលការយល់ព្រមពីរដ្ឋាភិបាលដើម្បីរឹតបន្តឹងចំពោះការផ្លាស់ទីរបស់ពួកគេ។ជនរងគ្រោះក៏ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលស្នាក់នៅបិទទ្វារផងដែរ ដោយផ្អែកលើហេតុផល ពួកគេនឹងមានវត្តមានដើម្បីចូលរួមនៅក្នុងការស៊ើបអង្កេត និងការផ្តន្ទាទោស។[37]

**គន្លឹះទី ១៣៖**
ការកសាងទំនុកចិត្ត គឺជាការចាំបាច់ឆ្ពោះទៅរកការទទួលបានការសហការរបស់ជនរងគ្រោះ។ ការចាប់ខ្លួន និង/ឬការឃុំខ្លួនអាចនាំទៅរកឧបសគ្គធ្ងន់ធ្ងរ ឬបំផ្លាញឱកាស ដើម្បីកសាងទំនុកចិត្តរបស់ជនរងគ្រោះ។

**គន្លឹះទី ១៤៖**
ផ្តល់ដល់ជនរងគ្រោះ និងសាក្សីដែលមិនមែនជាពលរដ្ឋនូវកិច្ចការពារយ៉ាងគ្រប់គ្រាន់ និងការអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្ននៅក្នុងអំឡុងពេលនៃកិច្ចដំណើរការផ្លូវច្បាប់។[38]

**គន្លឹះទី ១៥៖**
រិះរកវិធីនានាដើម្បីទទួលបានចម្លើយ និងសក្ខីកម្មជាភស្តុតាងពីជនរងគ្រោះដោយគ្មានការឃុំខ្លួនពួកគេក្នុងរយៈពេលវែងនៅក្នុងមណ្ឌលស្នាក់នៅ។[39] ការធ្វើបែបនេះ អាចរួមមានការប្រើប្រាស់ការផ្តល់សក្ខីកម្មមុនពេលជំនុំជម្រះ ការថតវីដេអូនៃការផ្តល់សក្ខីកម្ម ឬការផ្តល់សក្ខីកម្មតាមរយៈវីដេអូ។ ប្រសិនបើជនរងគ្រោះមានបំណង ឬអាចចូលរួមផ្តល់សក្ខីកម្មបាន គប្បីប្រើប្រាស់មធ្យោបាយផ្តល់សក្ខីកម្មមុនពេលជំនុំជម្រះ តំណភ្ជាប់វីដេអូ និងសវនការឆាប់រហ័ស ទៅតាមច្បាប់ដែលមាន ដើម្បីជួយបង្រួមរយៈពេលនៃការស្នាក់នៅជាកំហិតនៅក្នុងមណ្ឌលស្នាក់នៅបិទទ្វារ។[40]

37 McAdam (2020).

38 សញ្ញា ACTIP មាត្រា ១៤(៤) និង១៤(៥), កញ្ចប់ឧបករណ៍អាស៊ានស្តីពីគំរូសម្រាប់ការអនុវត្តរបស់អ្នកអនុវត្តការងារ (ឆ្នាំ២០១៩)។

39 ACWC Regional Review Recommendation 5.1, 5.2 and 5.3. See also Office of the High Commissioner for Human Rights. Recommended Principles and Guidelines on Human Rights and Human Trafficking. (n.d.) https://www.ohchr.org/Documents/Publications/Traffickingen.pdf

40 ការពិនិត្យឡើងវិញថ្នាក់តំបន់របស់ ACWC អនុសាសន៍ ៤.១។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការរងគ្រោះឡើងវិញនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការតុលាការ

សូម្បីតែនៅពេលដែលជនរងគ្រោះបានយល់ព្រមដោយស្ម័គ្រចិត្ត ក្នុងការចូលរួមយ៉ាងពេញលេញនៅក្នុងដំណើរការតុលាការក្តី ក៏ជនរងគ្រោះនៅតែងាយរងគ្រោះចំពោះការបំភិតបំភ័យនៅក្នុង និងនៅជុំវិញតុលាការដែរ។ ពួកគេអាចទទួលរងឥទ្ធិពលពីគេដោយងាយ ភាពអាចជឿបានរបស់ពួកគេអាចទទួលរងការបំផ្លាញដោយមេធាវីការពារក្តីដ៏ខ្លាំងក្លា ឬ ជនជួញដូរអាចបញ្ចុះបញ្ចូលពួកគេឱ្យដកការសហការរបស់ពួកគេវិញ ទោះជាតាមរយៈសំណូក ឬការបំភិតបំភ័យទៅលើជនរងគ្រោះ និង/ឬគ្រួសាររបស់ពួកគេក្តី។[41] អ្នកទាំងឡាយ ដែលទទួលរងការបង្ខំឱ្យប្រឈមមុខជាមួយជនជួញដូរពួកគេ អាចក្លាយជាជនគ្រោះសារជាថ្មីនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនេះ។

41 Anti-Slavery International (2002).

### គន្លឹះទី ១៦៖

កិច្ចដំណើរការស៊ើបអង្កេតដែលចាំបាច់ត្រូវធ្វើការពិនិត្យ និងការវាយតម្លៃលើរាងកាយ និងផ្លូវចិត្ត គប្បីកើតឡើងតែក្នុងករណី ដែលមានការយល់ព្រមប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនរងគ្រោះប៉ុណ្ណោះ។ ជនរងគ្រោះគប្បីទទួលបានព័ត៌មានអំពីជំហាន និងដំណើរការពាក់ព័ន្ធ និងមូលហេតុដែលចាំបាច់ត្រូវធ្វើបែបនេះ។ ការស្ងៀមស្ងាត់របស់ជនរងគ្រោះមិនគប្បីត្រូវបានបកស្រាយថា ជាការយល់ព្រមឡើយ។ ការពិនិត្យ និងការការវាយតម្លៃក៏គប្បីត្រូវបានធ្វើឡើងដោយនរណាម្នាក់ដែលមានយេនឌ័រដែលជនរងគ្រោះមានអារម្មណ៍សុខស្រួលជាមួយផងដែរ។

### គន្លឹះទី ១៧៖

ប្រសិនបើអាចធ្វើបាន ចាត់តាំង "អ្នកគាំទ្រជនរងគ្រោះ-សាក្សី" ឬ "អ្នកសម្របសម្រួលជនរងគ្រោះ-សាក្សី" ដើម្បីអមដំណើរ និងគាំទ្រជនរងគ្រោះនៅទូទាំងកិច្ចដំណើរការតុលាការ។ បុគ្គលនេះអាចផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីស្ថានភាពនៃករណី និងព័ត៌មានអំពីការបញ្ជូនទៅរកសេវានានា។[42]

### គន្លឹះទី ១៨៖

ស្នើសុំវិធានការគាំទ្រជាក់ស្តែងរបស់តុលាការ ដែលសំដៅកាត់បន្ថយការថប់បារម្ភ និងការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះ ដូចជា ការទៅកាន់បន្ទប់តុលាការនៅមុនពេលជំនុំជម្រះដើម្បីឱ្យពួកគេស្គាល់ច្បាស់អំពីបរិយាកាសជុំវិញ និងដឹងថាតើអ្នកណាអង្គុយកន្លែងណា ការអមដំណើរទៅ និងមកពីអាគារតុលាការ ការប្រើប្រាស់ច្រកចូលដោយឡែកទៅក្នុងអាគារតុលាការ កន្លែងរង់ចាំឯកជន និងការផ្តល់ព័ត៌មានជាប្រចាំពាក់ព័ន្ធនឹងការធ្វើការជំនុំជម្រះពីខាងអយ្យការនៅទូទាំងកិច្ចដំណើរការតុលាការ។[43]

42 កញ្ចប់ឧបករណ៍អាស៊ានស្តីពីគំរូសម្រាប់ការអនុវត្តរបស់អ្នកអនុវត្តការងារ (ឆ្នាំ២០១៩)។

43 គោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តការងារ ផ្នែកទី១ ច៤។ គោលការណែនាំអាស៊ានពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ចំពោះយេនឌ័រ កថាខណ្ឌ ៣.៦។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ការស៊ើបអង្កេត និងសេចក្តីសម្រេចចិត្តរបស់តុលាការ ដោយផ្អែកលើភាពលម្អៀង និង បុរេនិច្ឆ័យ

បុរេនិច្ឆ័យជារួមអំពីទំនាក់ទំនងនៃបញ្ហាយេនឌ័រ និងទម្រង់ដទៃទៀតនៃការរើសអើង អាចរារាំងជនរងគ្រោះពីការទទួលបានភាពយុត្តិធម៌។ ឧទាហរណ៍ បុគ្គលម្នាក់ដែលមានពិការភាពផ្លូវចិត្តអាចត្រូវបានសន្មតជាមុនថា ជាសាក្សីអសមត្ថភាព ឬមិនអាចទុកចិត្តបាន។ បុរេនិច្ឆ័យអាចប៉ះពាល់ដល់ភាពឥតលម្អៀងរបស់តួអង្គតុលាការ សេចក្តីសម្រេចរបស់ចៅក្រម និងព្រះរាជអាជ្ញា ព្រមទាំងការយល់ឃើញរបស់ពួកគេចំពោះភាពអាចទុកចិត្តបានរបស់សាក្សី និង/ឬសមត្ថភាពផ្លូវច្បាប់របស់សាក្សី។

**គន្លឹះទី ១៩៖**

ចៅក្រម និងមេធាវីការពារត្រូវតែប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងការអនុវត្តលក្ខណៈវិជ្ជាជីវៈរបស់ពួកគេ។ ការធ្វើបែបនេះរួមមានការជៀសវាងពីការប្រើប្រាស់ភាសា ឬសំនៀងបែបវាយប្រហារ ឬកម្រោល។ បន្ថែមលើនេះ មិនគប្បីជំរុញឱ្យជនរងគ្រោះរំឭកអំពីរឿងរ៉ាវរបស់ពួកគេឡើយ។

**គន្លឹះទី ២០៖**

បណ្តុះបណ្តាលអ្នកវិជ្ជាជីវៈផ្នែកយុត្តិធម៌ព្រហ្មទណ្ឌអំពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបុរេនិច្ឆ័យអំពីយេនឌ័រ និងភាពលម្អៀងចំពោះយេនឌ័រ។ គូសបញ្ជាក់អំពីការបង្កគ្រោះថ្នាក់នៃការយល់ឃើញជាបុរេនិច្ឆ័យរបស់តុលាការ តាមរយៈការស្រាវជ្រាវដែលផ្អែកលើភស្តុតាង។ វិភាគការវែកញែករបស់តុលាការចំពោះភស្តុតាងពីការយល់ឃើញជាបុរេនិច្ឆ័យ និងគូសបញ្ជាក់ឧទាហរណ៍នៃការអនុវត្តល្អៗរបស់តួអង្គផ្នែកយុត្តិធម៌ ដែលបានតតាំង និងបានជំនះលើការយល់ឃើញជាបុរេនិច្ឆ័យចំពោះយេនឌ័រ។

## គ្រោះថ្នាក់ដែលអាចកើតឡើង៖ ភាពតានតឹងផ្នែកសេដ្ឋកិច្ច និងបដិទាន និងសំណងនៅមានកម្រិត

ការចូលរួមនៅក្នុងដំណើរការផ្លូវច្បាប់ អាចបង្កឱ្យមានបន្ទុកចំណាយផ្នែកហិរញ្ញវត្ថុច្រើនចំពោះជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។ សម្រាប់ជនរងគ្រោះជាច្រើន ដែលជាអ្នកប្រកបរបរចិញ្ចឹមគ្រួសារតែម្នាក់ឯង ស្ថានភាពនេះបង្កើតភាពតានតឹងផ្នែកសេដ្ឋកិច្ច ផ្លូវអារម្មណ៍ និងផ្លូវចិត្តយ៉ាងខ្លាំង។ ការផ្តន្ទាទោសជនជួញដូរប្រកបដោយជោគជ័យអាចមិននាំទៅដល់បដិទាន ឬសំណងសម្រាប់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេទេ។ អត្ថប្រយោជន៍នៃការជួយជាមួយនឹងកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ មិនមានលក្ខណៈច្បាស់លាស់ចំពោះជនរងគ្រោះជាច្រើន។

**គន្លឹះទី ២១៖**

កុំសន្យាជ្រុលពេក ឬនិយាយបំផ្លើសអំពីផលប្រយោជន៍នៃការចូលរួមនៅក្នុងកិច្ចដំណើរការផ្លូវច្បាប់។ សេវាការពារ និងសេវាគាំទ្រ ដូចជាជំនួយផ្នែកវេជ្ជសាស្ត្រ និងមណ្ឌលស្នាក់នៅ (រួមទាំងកន្លែងស្នាក់នៅបណ្តោះអាសន្ន) គប្បីត្រូវកាត់ផ្តាច់ចេញពីគោលបំណងផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ។

**គន្លឹះទី ២២៖**

ផ្តល់ព័ត៌មានច្បាស់លាស់អំពីឧបាស្រ័យដោយប្រើប្រាស់ភាសា និងទម្រង់ដែលជនរងគ្រោះអាចយល់បានដោយងាយស្រួល។ ការធ្វើបែបនេះអាចរួមមាន៖ សិទ្ធិរបស់ពួកគេក្នុងការទទួលបានឧបាស្រ័យ ជាពិសេស សម្រាប់ជនរងគ្រោះដែលស្នាក់នៅក្រៅប្រទេសដើមរបស់ខ្លួន ដំណើរការដាក់ពាក្យសុំ និងសំណុំឯកសារដែលចាំបាច់ ការប៉ាន់ប្រមាណ និងពេលវេលាសម្រាប់ការអនុម័ត។ល។ ជនរងគ្រោះ ដែលមិនមែនជាពលរដ្ឋគប្បីទទួលបានសិទ្ធិបន្តស្ថិតនៅក្នុងប្រទេសនោះ រួមទាំងសិទ្ធិក្នុងការធ្វើការងារ ប្រសិនបើពួកគេមានបំណងធ្វើការ រហូតដល់មានដំណោះស្រាយសម្រាប់ការទាមទារសំណងរបស់ពួកគេ។[45]

**គន្លឹះទី ២៣៖**

សម្រេចផ្តល់បដិទាន និងសំណង ប្រសិនបើជនជួញដូរបានគេចខ្លួន ឬ "គ្មានលុយ" ក៏ដោយ។

44 Ibid.

45 UNICEF. Guidelines on the Protection of Child Victims of Trafficking. UNICEF Technical Notes (New York: 2006).https://ec.europa.eu/antitrafficking/sites/antitrafficking/files/unicef_guidlines_on_protection_of_the_rights_of_teh_child_2006_en_2.pdf

## ការធ្វើការជាមួយកុមារៈ គន្លឹះសម្រាប់ការមិនបង្កគ្រោះថ្នាក់

អាស្រ័យលើអាយុ ភាពចាស់ទុំ និងបទពិសោធន៍របស់ពួកគេអំពីអំពើជួញដូរមនុស្ស កុមារត្រូវដែលត្រូវបានគេជួញដូរមានតម្រូវការជំនួយដែលតម្រូវឱ្យមានការថែទាំឯកទេសខ្ពស់។ អ្នកអនុវត្តការងារចាំបាច់ត្រូវទទួលស្គាល់ថា មិនមែនកុមាររងគ្រោះដោយអំពើជួញដូរទាំងអស់នឹងបង្ហាញថាពួកគេ គឺសុទ្ធតែមានលក្ខណៈដូច្នេះទេ។ ពួកគេអាចមានឯកសារសម្គាល់ខ្លួនក្លែងក្លាយ ដែលបំភ្លៃអំពីអាយុរបស់ពួកគេ ឬអាចកុហកអំពីអាយុរបស់ពួកគេ ដោយសារអ្នកកេងប្រវ័ញ្ចពួកគេប្រាប់ឱ្យនិយាយបែបនេះ។ ដោយសារកុមាររងគ្រោះដោយអំពើជួញដូរ កម្រអាចគេចខ្លួនចេញពីស្ថានភាពកេងប្រវ័ញ្ចបាន ពួកគេពឹងផ្អែកលើវិធានការកំណត់អត្តសញ្ញាណបែបបុរេសកម្មដែលអនុវត្តដោយស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ រដ្ឋសមាជិកអាស៊ានត្រូវបានតម្រូវឱ្យរៀបចំច្បាប់ គោលនយោបាយ និងយន្តការសមស្រប ដើម្បីធានាសុវត្ថិភាព និងសុខុមាលភាពរបស់កុមាររងគ្រោះនៅគ្រប់ដំណាក់កាល ពោលគឺ ចាប់តាំងពីការកំណត់អត្តសញ្ញាណរហូតដល់រកបានដំណោះស្រាយយូរអង្វែង។

**គន្លឹះទី ១៖**

ជនរងគ្រោះម្នាក់ដែលមិនច្បាស់អំពីអាយុរបស់ពួកគេ គប្បីត្រូវបានសន្មតជាមុនថាជាកុមារ ហើយដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះ និងសម្ភាសន៍គប្បីមានសង្គតភាពជាមួយនឹងគោលការណ៍នានានៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)។ ការកំណត់អត្តសញ្ញាណជនរងគ្រោះត្រូវអនុវត្តយ៉ាងរហ័សនិងទទួលបានការចាត់ជាអាទិភាព ដើម្បីកំណត់អាយុរបស់ជនរងគ្រោះ ដើម្បីធានាថា សេវាដែលត្រូវផ្តល់ដល់ជនរងគ្រោះ គឺជាសេវាសមស្រប។[46]

**គន្លឹះទី ២៖**

ក្នុងកម្រិតខ្ពស់បំផុតដែលអាចធ្វើបាន មានតែបុគ្គលិកដែលទទួលបានការបណ្តុះបណ្តាលអំពីតម្រូវការពិសេស និងសិទ្ធិរបស់កុមារប៉ុណ្ណោះដែលគប្បីចាត់ចែង ឬសម្ភាសន៍កុមាររងគ្រោះ។

**គន្លឹះទី ៣៖**

កុមារដែលត្រូវបានគេជួញដូរគប្បីទទួលបានការចាត់តាំងអាណាព្យាបាលស្របច្បាប់ ដើម្បីណែនាំពួកគេ និងការពារសិទ្ធិ និងផលប្រយោជន៍របស់ពួកគេ នៅពេលណាដែលឪពុកម្តាយរបស់ពួកគេមិនអាចចូលរួមជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ មិនមានបំណង ឬមិនស័ក្តិសមក្នុងការប្រើប្រាស់សិទ្ធិឪពុកម្តាយរបស់ពួកគេ។ អាណាព្យាបាលដែលត្រូវបានចាត់តាំងគប្បីទទួលបានការពិគ្រោះយោបល់ និងព័ត៌មានអំពីវិធានការទាំងអស់ដែលត្រូវបានអនុវត្តពាក់ព័ន្ធនឹងកុមារ។

**គន្លឹះទី ៤៖**

ព័ត៌មានទាំងអស់ដែលត្រូវផ្តល់ដល់កុមារ ចាំបាច់ត្រូវសមស្របជាមួយនឹងអាយុ ភាពចាស់ទុំ កម្រិតនៃការអប់រំ និងបទពិសោធន៍របស់កុមារ និងបង្ហាញដល់កុមារក្នុងលក្ខណៈកុមារមេត្រី និងសមស្រប។ លើកទឹកចិត្ត និងធានាថា រាល់សេចក្តីសម្រេចចិត្តទាំងអស់ត្រូវបានធ្វើឡើងដោយមានការចូលរួម និងធាតុចូលរបស់កុមារ។ កម្រិតដែលកុមារអាចផ្តល់ការយល់ព្រមប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយ នឹងមានលក្ខណៈខុសៗគ្នា ដោយយោងទៅតាមអាយុ បទពិសោធន៍ និងដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ។ សូមចងចាំអំពីផលប៉ះពាល់ដែលអាចកើតឡើងនៃអតុល្យភាពអំណាចរវាងកុមារ និងមនុស្សពេញវ័យ រួមទាំងប្រការដែលថាតើអតុល្យភាពនេះបង្កើតសម្ពាធទៅលើការយល់ព្រម ដែរឬទេ (ដោយបុគ្គលិក ឬឪពុក ឬម្តាយ/អាណាព្យាបាល)។[48]

46 គោលការណែនាំអាស៊ានពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ចំពោះយេនឌ័រ កថាខណ្ឌ ៣.២.៣។ ការពិនិត្យឡើងវិញថ្នាក់តំបន់របស់ ACWC អនុសាសន៍ ២.២។

47 UNICEF (2006).

48 Surtees, R. Ethical principles for the re/integration of trafficked persons: Experiences from the Balkans. Issue Paper #5. (Nexus Institute: 2013).

**គន្លឹះទី ៥៖**

អនុញ្ញាតឱ្យកុមារដែលត្រូវបានឃុំខ្លួន ចាប់ខ្លួន សង្ស័យ ឬចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌទាក់ទងជាមួយឪពុកម្តាយ ឬ អាណាព្យាបាលរបស់ពួកគេភ្លាម និងហាមឃាត់ការសម្ភាសជាមួយកុមារដោយគ្មានវត្តមានរបស់មេធាវី ឬអ្នកផ្តល់ជំនួយផ្នែកច្បាប់ដទៃទៀត និងឪពុក ឬម្តាយ ឬអាណាព្យាបាល ( នៅពេលអាចធ្វើបាន ) ដើម្បីឧត្តមប្រយោជន៍របស់កុមារ។[49]

**គន្លឹះទី ៦៖**

កុមារត្រូវតែទទួលបានព័ត៌មានក្នុងលក្ខណៈមួយដែលសមស្របទៅតាមអាយុ និងភាពចាស់ទុំរបស់កុមារ។ ការផ្តល់ព័ត៌មានដល់ឪពុកម្តាយអាណាព្យាបាលឬអ្នកថែទាំគប្បីជាការបន្ថែម និងមិនមែនជាការជំនួសឡើយ ដើម្បីផ្តល់ព័ត៌មានទៅដល់កុមារ។[50]

**គន្លឹះទី ៧៖**

រៀបចំការសម្ភាសជាមួយកុមារដោយមានវត្តមានរបស់មនុស្សពេញវ័យដែលកុមារទុកចិត្តនៅជាមួយ។ ទំនួលខុសត្រូវរបស់ជននេះ គឺដើម្បីរក្សាឧត្តមប្រយោជន៍របស់កុមារ។ ជននេះអាចជាអាណាព្យាបាលអ្នកតំណាងស្របច្បាប់ ឬក្នុងករណីគ្មានការចាត់តាំងអាណាព្យាបាល ឬអ្នកតំណាងស្របច្បាប់ ជននេះអាចជាគ្រូបង្រៀន ឬបុគ្គលិកសង្គម។[51]

**គន្លឹះទី ៨៖**

សួរសំណួរ ដែលពិចារណាលើចរិតលក្ខណៈ និងសាវតារគ្រួសាររបស់កុមារ។ គប្បីប្រើប្រាស់ភាសាបែបកុមារមេត្រី។ កុមារគប្បីទទួលបានឱកាសមួយដើម្បីប្រាប់រឿងរ៉ាវរបស់ពួកគេទៅតាមរបៀបរបស់ខ្លួនពួកគេផ្ទាល់ មុនពេលសួរសំណួរជាក់លាក់ទៅកាន់ពួកគេ។ គ្រប់ការសម្ភាសគប្បីចាប់ផ្តើមជាមួយសំណួរបើក និងគប្បីទុកសំណួរដោយផ្ទាល់ ឬសំណួរនាំមុខ សម្រាប់ផ្នែកក្រោយទៀតនៃការសម្ភាស។

49 UNODC. United Nations Principles and Guidelines on Access to Legal Aid in Criminal Justice Systems. ( Vienna: 2013 ). See https://www.unodc.org/documents/justice-and-prison-reform/UN_principles_and_guidlines_on_access_to_legal_aid.pdf

50 UNODC ( 2013 )

51 ការពិនិត្យឡើងវិញថ្នាក់តំបន់របស់ ACWC

### គន្លឹះទី ៩៖
ធ្វើការប៉ាន់ប្រមាណឧត្តមប្រយោជន៍របស់កុមារភ្លាម បន្ទាប់ពីកំណត់ថាកុមារមានហានិភ័យ។ ត្រូវតែពិចារណាលើទស្សនៈរបស់កុមារអំពីការប៉ាន់ប្រមាណ និងដំណើរការនេះ។ កិច្ចការនេះគប្បីជាដំណើរការជាបន្តបន្ទាប់ ដោយចាត់ទុកឧត្តមប្រយោជន៍របស់កុមារជាចំណុចសំខាន់នៃវិធានការនានា និងជាការពិចារណាបឋម និងជាគោលបំណងនៃគ្រប់វិធានការដែលមានឥទ្ធិពលលើពួកគេ។[52]

### គន្លឹះទី ១០៖
ការឃុំខ្លួនកុមាររងគ្រោះមិនអាចត្រូវបញ្ជាក់ភាពត្រឹមត្រូវ ដោយផ្អែកតែលើមូលដ្ឋាននៃភាពគ្មានមនុស្សអមដំណើរកុមារ ឬកុមារបានបែកចេញពីគ្រួសារ ស្ថានភាពទេសន្តរប្រវេសន៍ ឬលំនៅដ្ឋានរបស់កុមារ ឬកង្វះស្ថានភាពណាមួយឡើយ។ ស្រដៀងគ្នានេះដែរ ជៀសវាងការទុកដាក់កុមាររងគ្រោះនៅក្នុងមណ្ឌលស្នាក់នៅ ឬមណ្ឌលសុខុមាលភាព និងធ្វើបែបនេះ តែនៅក្រោយពេលបានស្វែងរកជម្រើសថែទាំជំនួសដទៃទៀតអស់ប៉ុណ្ណោះ។ ការទុកដាក់បែបនេះគប្បីត្រូវធ្វើសម្រាប់រយៈពេលខ្លីបំផុតតាមដែលអាចធ្វើបាន និងគប្បីត្រូវពិនិត្យឡើងវិញយ៉ាងទៀងទាត់ដោយអាជ្ញាធរឯករាជ្យ។[53]

### គន្លឹះទី ១១៖
មិនត្រូវឱ្យមានការកំណត់ឃើញអត្តសញ្ញាណសម្គាល់ខ្លួនរបស់កុមាររងគ្រោះ និងត្រូវអនុវត្តគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីការពារឯកជនភាពរបស់កុមារ។[54] កុមារមិនមានសមត្ថភាពក្នុងការផ្តល់ការយល់ព្រមសម្រាប់ការចែកចាយ ការផ្សព្វផ្សាយ ឬការបង្ហាញនូវសម្ភារជាសំណេរ ឬជារូបភាពដែល កំណត់អត្តសញ្ញាណរបស់ពួកគេថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សឡើយ។ គេមិនត្រូវប្រើរូបភាពណាមួយរបស់ជនដែលត្រូវគេជួញដូរដែលជាកុមារទេពីព្រោះហានិភ័យដែលអាចធ្វើឱ្យមានការកំណត់សញ្ញាណសម្គាល់ខ្លួនរបស់ពួកគេបាន។

52 Office of the High Commissioner for Human Rights. Recommended Principles and Guidelines on Human Rights and Human Trafficking. (n.d.) https://www.ohchr.org/Documents/Publications/Traffickingen.pdf

53 កញ្ចប់ឧបករណ៍អាស៊ានស្តីពីគំរូសម្រាប់ការអនុវត្តរបស់អ្នកអនុវត្តការងារ (ឆ្នាំ២០១៩)។

54 គោលការណ៍ណែនាំ និងនីតិវិធីតំបន់របស់អាស៊ាន, ការពិនិត្យឡើងវិញថ្នាក់តំបន់របស់ ACWC។

**គន្លឹះទី ១២៖**

កុមារគប្បីទទួលបានព័ត៌មានពេញលេញ និងចូលរួមនៅក្នុងគ្រប់ការធ្វើសេចក្តីសម្រេចចិត្តអំពីការចូលរួមរបស់ពួកគេនៅក្នុងកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ រួមទាំងព័ត៌មានពាក់ព័ន្ធនឹងកាលវិភាគនៃការជំនុំជម្រះ សិទ្ធិរបស់ពួកគេក្នុងការទទួលបានជំនួយផ្លូវច្បាប់ និងការទទួលបានសំណង។ តួអង្គផ្នែកយុត្តិធម៌ និងអ្នកផ្តល់សេវាពាក់ព័ន្ធគប្បីទទួលបានការបណ្តុះបណ្តាលជាក់លាក់អំពីគោលការណ៍ និងការអនុវត្តការចូលរួមរបស់កុមារ និងកិច្ចការពារកុមារនៅក្នុងកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

**គន្លឹះទី ១៣៖**

ធានាថាកិច្ចដំណើរការតុលាការ និងរដ្ឋបាលត្រូវបានធ្វើឡើងនៅក្នុងបរិយាកាស និងលក្ខណៈមួយដែលអនុញ្ញាតឱ្យមានការស្តាប់ឮរបស់កុមារ ទោះជាស្តាប់ឮដោយផ្ទាល់ ឬតាមរយៈអ្នកតំណាង ឬអង្គភាពសមស្របក្នុងលក្ខណៈមួយដែលមានសង្គតភាពជាមួយនឹងវិធាននីតិវិធីនៃច្បាប់ជាតិក្តី។ ការពិចារណាអំពីអាយុ និងភាពចាស់ទុំរបស់កុមារក៏អាចទាមទារឱ្យមានការកែសម្រួលនីតិវិធីនិងការអនុវត្តផ្នែកតុលាការនិងរដ្ឋបាលផងដែរ។[55]

**គន្លឹះទី ១៤៖**

ឯកជនភាព និងទិន្នន័យផ្ទាល់ខ្លួនរបស់កុមារ ដែលចូលរួម ឬបានចូលរួមនៅក្នុងដំណើរការតុលាការ ឬដំណើរការក្រៅតុលាការ និងអន្តរាគមន៍ដទៃទៀត គប្បីទទួលបានកិច្ចការពារនៅគ្រប់ដំណាក់កាល ហើយកិច្ចការពារបែបនេះគប្បីត្រូវបានធានាដោយច្បាប់។ ជាទូទៅ ចំណុចនេះបង្កប់ន័យថា មិនមានការផ្តល់ ឬការបោះពុម្ពព័ត៌មាន ឬទិន្នន័យផ្ទាល់ខ្លួនឡើយ ជាពិសេស នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ដែលអាចបង្ហាញ ឬបង្កលក្ខណៈដោយប្រយោលឱ្យមានការបង្ហាញអត្តសញ្ញាណរបស់កុមារ រួមទាំងរូបភាពរបស់កុមារ សេចក្តីបរិយាយលម្អិតអំពីកុមារ ឬអំពីគ្រួសារ ឈ្មោះ ឬអាសយដ្ឋានរបស់សមាជិកគ្រួសារកុមារ និងសម្លេង ឬវីដេអូរបស់កុមារឡើយ។[56]

55 UNODC (2013).

56 UNODC (2013)

**គន្លឹះទី ១៥៖**

ការជួបជុំគ្រួសារ គឺជាជម្រើសទីមួយ និងជាទីចង់បានជាងគេនៅក្នុងការបំពេញតម្រូវការរបស់កុមារ។ គប្បីអនុវត្តជម្រើសនេះនៅក្នុងគ្រប់ស្ថានភាពទាំងអស់ ដែលត្រូវបានចាត់ទុកថាមានសុវត្ថិភាព និងសុខភាពល្អសម្រាប់កុមារ។ នៅពេលមិនអាចអនុវត្តជម្រើសនេះបាន ការទុកដាក់ក្នុងការថែទាំជំនួសអាចរួមមានការថែទាំដោយសាច់ញាតិ/ការទុកដាក់ជាមួយសាច់ញាតិ ការថែទាំកុមារដោយឪពុកម្តាយធម៌ ផ្ទះស្នាក់នៅជាក្រុមតូចៗ។ល។ មណ្ឌលស្នាក់នៅ និងមណ្ឌលថែទាំកុមារគប្បីត្រូវចាត់ទុកថាជាជម្រើសចុងក្រោយនៅក្នុងករណីនៃកុមារដែលត្រូវបានគេជួញដូរ ហើយនៅពេលចាំបាច់ គប្បីជាដំណោះស្រាយបណ្តោះអាសន្ន។ ដោយសារកុមារ និងយុវជន គឺជាក្រុមចម្រុះមួយ (មានលក្ខណៈខុសៗគ្នាទៅតាមអាយុ យេនឌ័រ ភាពចាស់ទុំ ដំណាក់កាលនៃការអភិវឌ្ឍ បទពិសោធន៍នៃអំពើជួញដូរ ស្ថានភាពផ្ទាល់ខ្លួនរបស់ពួកគេ និងស្ថានភាពគ្រួសាររបស់ពួកគេ និងសេចក្តីត្រូវការជំនួយរបស់ពួកគេ) គប្បីមានជម្រើសនៃការស្នាក់នៅច្រើនចម្រុះគ្នា។

**គន្លឹះទី ១៦៖**

សេវានានាដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មរបស់កុមារដែលត្រូវបានគេជួញដូរ ត្រូវតែបានរៀបចំទៅតាមតម្រូវការផ្ទាល់ខ្លួន និងជាក់លាក់របស់ពួកគេ និងត្រូវបានរៀបចំ និងអនុវត្តក្នុងលក្ខណៈកុមារមេត្រី។[57] គោលការណ៍សិទ្ធិកុមារ និងពិធីសារជាក់លាក់ស្តីពីកុមារគប្បីជាមូលដ្ឋានសម្រាប់ការងារនេះ។

57 ការពិនិត្យឡើងវិញថ្នាក់តំបន់របស់ ACWC

# ក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់៖ គន្លឹះសម្រាប់ការមិនបង្កគ្រោះថ្នាក់

ស្ថានភាពយេនឌ័រ និងសេដ្ឋកិច្ចសង្គមរបស់បុគ្គលម្នាក់កំណត់អំពីភាពងាយរងគ្រោះចំពោះអំពើជួញដូរមនុស្ស។ ក្រុមមួយចំនួន ដោយសារយេនឌ័រ កត្តាផ្លូវភេទ អាយុ ជាតិពន្ធុ សាសនា ប្រាក់ចំណូលក្នុងគ្រួសារ កម្រិតវប្បធម៌ ស្ថានភាពជាពលរដ្ឋ និងពិការភាពរបស់ពួកគេ អាចមានភាពងាយរងគ្រោះច្រើនជាងចំពោះអំពើជួញដូរមនុស្ស។ ក្នុងការកំណត់ "ភាពងាយរងគ្រោះ" អង្គការ UNODC ពិចារណាលើស្ថានភាពផ្ទាល់ខ្លួន ស្ថានភាព ឬកាលៈទេសៈរបស់ជនរងគ្រោះ។[58] ក្នុងពេលជាមួយគ្នានេះដែរ ស្ថានភាពយេនឌ័រ និងសេដ្ឋកិច្ចសង្គមរបស់ជនរងគ្រោះដោយអំពើជួញដូរក៏មានឥទ្ធិពលលើសមត្ថភាពរបស់ពួកគេក្នុងការទទួលបានសិទ្ធិ កិច្ចការពារ និងជំនួយផងដែរ។

ការរាតត្បាតមេរោគកូវីដ ១៩ ដែលកំពុងកើតឡើង នឹងធ្វើឱ្យភាពងាយរងគ្រោះរបស់ជនចំណាកស្រុក និងក្រុមជនជួបការលំបាកផ្សេងទៀតនៅអាស៊ីអគ្នេយ៍ មានលក្ខណៈកាន់តែធ្ងន់ធ្ងរ និងបង្កលក្ខខណ្ឌនានាដែលបណ្តាលឱ្យមានការជួញដូរមនុស្ស និងបង្កើនលក្ខខណ្ឌសម្រាប់អំពើជួញដូរមនុស្ស និងទាសភាពបែបទំនើប។ ការកើនឡើងយ៉ាងខ្លាំងនៃភាពគ្មានការងារដែលបង្កឡើងដោយជំងឺកូវីដ ១៩ មានន័យថា ជនជួញដូរមនុស្ស និងអ្នកជ្រើសរើស ឈ្មួញកណ្តាល និងនិយោជកទុច្ចរិត នឹងមិនមានការលំបាកក្នុងការកំណត់គោលដៅលើជនរងគ្រោះ ដែលមិនសូវទទួលបានការយកចិត្តទុកដាក់ ស្ថិតនៅក្នុងស្ថានភាពលំបាក ឬដែលកំពុងត្រូវការការងារខ្លាំងឡើយ។[59]

58 UNODC. 'Guidance note on 'abuse of a position of vulnerability' as a means of trafficking in persons in Article 3 of the Protocol to Prevent, Suppress and Punish Trafficking in Persons, Especially Women and Children, supplementing the United Nations Convention against Transnational Organised Crime' (Vienna: 2012), paragraph 2.3. See https://www.unodc.org/documents/human-trafficking/2012/UNODC_2012_Guidance_Note_-_Abuse_of_a_Position_of_Vulnerability_E.pdf

59 United Nations Office for Drugs and Crime. Global Report on Trafficking in Persons 2020. (Vienna: 2020). https://www.unodc.org/documents/data-and-analysis/tip/2021/GLOTiP_2020_15jan_web.pdf

**គន្លឹះទី ១៖**

អ្នកសម្ភាសន៍ និងអ្នកផ្តល់សេវាត្រូវតែប៉ាន់ប្រមាណថា តើពួកគេមានការយល់ឃើញជាមុនបែបអវិជ្ជមាន ភាពលម្អៀង ឬអារម្មណ៍ប្រកាន់ពូជសាសន៍អំពីបុគ្គលនានាដែលពួកគេនឹងសម្ភាសន៍/ជួយដែរឬទេ និងចាត់វិធានការដើម្បីធានាឱ្យបានថាចំណុចទាំងនេះមិនមានឥទ្ធិពលជាអវិជ្ជមានលើសេវានិងការគាំទ្រដែលផ្តល់ជូនជនរងគ្រោះឡើយ។

**គន្លឹះទី ២៖**

ផ្តល់អ្នកបកប្រែភាសាសម្រាប់ជនរងគ្រោះមកពីក្រុមជនជាតិភាគតិច និងជនទាំងឡាយដែលមានពិការភាព។ ធានាឱ្យបានថាជនរងគ្រោះមានអារម្មណ៍មានផាសុកភាពជាមួយនឹងយេនឌ័ររបស់អ្នកបកប្រែ និងថាអ្នកបកប្រែមិនស្គាល់ជនរងគ្រោះ។

**គន្លឹះទី ៣៖**

ផ្តល់ដល់ស្ត្រី កុមារី និងយុវនារីនូវជម្រើសនៃការសម្ភាស ឬការជួបជាមួយអ្នកអនុវត្តការងារជាស្ត្រី។ ប្រសិនបើមិនមានអ្នកអនុវត្តការងារជាស្ត្រីទេ ស្ត្រីម្នាក់គប្បីមានវត្តមាន នៅក្នុងអំឡុងពេលនៃការសម្ភាស និងការពិនិត្យ។ ស្រដៀងគ្នានេះដែរ ការផ្តល់ដល់បុរស និងកុមារាវ័យជំទង់នូវជម្រើសនៃការសម្ភាស ឬការជួបជាមួយអ្នកអនុវត្តការងារជាបុរសគឺមានសារសំខាន់ដូចគ្នា។[60]

**គន្លឹះទី ៤៖**

ដោយសារស្ថានភាពងាយរងគ្រោះផ្នែកសង្គមរបស់ពួកគេ ហានិភ័យជាច្រើនពាក់ព័ន្ធនឹងការចូលរួមរបស់ក្រុមដែលមិនសូវទទួលបានការយកចិត្តទុកដាក់នៅក្នុងកិច្ចដំណើរការផ្លូវច្បាប់ គប្បីត្រូវបានប៉ាន់ប្រមាណ និងពិភាក្សាយ៉ាងម៉ត់ចត់ជាមួយជនរងគ្រោះ នៅមុនពេលអនុវត្តការចូលរួមនេះ។ សិទ្ធិរបស់ពួកគេចំពោះការយល់ព្រមប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយ ការរក្សាការសម្ងាត់ និងឯកជនភាព ត្រូវអនុវត្តនៅទីនេះ។

**គន្លឹះទី ៥៖**

ផ្តល់ជំនួយពិសេស ដូចជា អាណាព្យាបាលស្របច្បាប់សម្រាប់បុគ្គលដែលមានពិការភាពផ្នែកសតិ ពិការភាពផ្លូវចិត្ត ឬបុគ្គលដែលមិនអាចចូលរួមយ៉ាងពេញលេញ នៅក្នុងនីតិវិធីនៃការយល់ព្រមប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយបាន។ អាណាព្យាបាលស្របច្បាប់គឺជាជនម្នាក់ដែលមានលិខិតប្រគល់សិទ្ធិអំណាច ដែលផ្តល់ដោយបុគ្គលនេះ ឬអ្នកការពារផ្លូវច្បាប់របស់បុគ្គលនេះ ដែលមានលិខិតប្រគល់សិទ្ធិអំណាចបែបនេះជាលាយលក្ខណ៍អក្សរ។ អង្គការនានាគប្បីពិគ្រោះយោបល់ជាមួយមេធាវីពាក់ព័ន្ធនឹងការយល់ព្រមរបស់បុគ្គលនានា ដែលមិនអាចផ្តល់ការយល់ព្រមដែលមានសុពលភាពផ្លូវច្បាប់បាន ដោយសារស្ថានភាពផ្នែកសតិ ឬផ្លូវកាយ។[61]

60 IOM (2007)

61 IOM (2007)

**គន្លឹះទី ៦៖**
គប្បីគូសបញ្ជាក់នូវតម្រូវការពិសេសរបស់ក្រុមងាយរងគ្រោះក្នុងលក្ខណៈ មិនបំផ្លើស និងមិនលម្អៀង ដោយមិនប្រើភាសាដែលបង្ហាញនូវភាព អាណិត ឬភាពអាម៉ាស់។

**គន្លឹះទី ៧៖**
គប្បីផ្តល់ព័ត៌មានទាំងអស់ក្នុងលក្ខណៈឆ្លើយតបចំពោះតម្រូវការរបស់ ជនដែលមិនចេះអក្សរ ហើយព័ត៌មានទាំងនោះគប្បីត្រូវបានផ្តល់ជា ភាសាដែលបុគ្គលទាំងនោះយល់បាន។

**គន្លឹះទី ៨៖**
ជនរងគ្រោះគប្បីទទួលបានព័ត៌មានពេញលេញអំពីសិទ្ធិ ជម្រើស និង ឱកាសនានា និងចូលរួមយ៉ាងសកម្មនៅក្នុងសេចក្តីសម្រេចចិត្តទាំងអស់ អំពីសេវានានាដែលពួកគេចង់ (ឬមិនចង់) ទទួល។[62]

**គន្លឹះទី ៩៖**
ត្រូវដឹងអំពីនិយាមសង្គម ដែលមានផលប៉ះពាល់អវិជ្ជមានលើស្ត្រី និង បញ្ហាប្រឈមជាក់លាក់ ដែលជនរស់រានផុតពីការជួញដូរជាស្ត្រី បុរស និងកុមារជួបប្រទះ និងធានាថា សេវាទាំងអស់ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបចំពោះទិដ្ឋភាពទាំងនេះ ដូចជា ការគាំទ្រផ្នែកចិត្តសង្គម ព័ត៌មានផ្លូវច្បាប់ ភាពតំណាង មណ្ឌលស្នាក់នៅមានសុវត្ថិភាព។[63]

**គន្លឹះទី ១០៖**
ធានាថា ជនរងគ្រោះមានលទ្ធភាពទទួលបានសេវាពហុវិស័យគ្រប់ជ្រុង ជ្រោយ ដែលឆ្លើយតបចំពោះយេនឌ័រ ដូចជា ការផ្តល់ប្រឹក្សាផ្នែកចិត្ត សង្គម ជំនួយផ្លូវច្បាប់ សុខភាពបន្តពូជ សុខភាពផ្លូវភេទ និងសេវាសង្គម លំហសម្រាប់តែស្ត្រី ការគាំទ្រពីមិត្តភក្តិ និងលទ្ធភាពមានមណ្ឌលស្នាក់ នៅ ឬផ្ទះស្នាក់នៅបណ្តោះអាសន្នរបស់ស្ត្រី។

62 Surtees, R. Supporting the Reintegration of Trafficked Persons: A Guidebook for the Greater Mekong Sub-Region. (Bangkok: NEXUS Institute, UN-ACT and World Vision, 2017).

63 Ibid

### គន្លឹះទី ១១៖
ជានាថា កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ជំនាញជៀសវាងការគូសបង្ហាញបុរេនិច្ឆ័យអំពីយេនឌ័រ ដែលមានហានិភ័យធ្វើឱ្យស្ត្រីជាប់នៅក្នុងការងារមានចំណូលទាប និងប្រកបដោយការកេងប្រវ័ញ្ច។ ដើម្បីធ្វើបែបនេះបាន ការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញ គប្បីមានចេតនាដោះស្រាយបញ្ហាបែងចែកប្រភេទការងារ តាមរយៈការផ្តល់ការបណ្តុះបណ្តាលអំពីការងារ និងវិស័យដែលផ្តល់ចំណេញខ្ពស់ និងដែលមានផល និងគុណភាពខ្ពស់ និងគាំទ្រស្ត្រីយ៉ាងសកម្មក្នុងការចូលរួមនៅក្នុងការបណ្តុះបណ្តាលនេះ ប្រសិនបើពួកគេមានបំណងចូលរួម។[64]

### គន្លឹះទី ១២៖
ដាក់ឱ្យអនុវត្តនូវវិធានការនានា ដែលដោះស្រាយការមាក់ងាយលើជនរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ និងអ្នកទាំងឡាយ ដែលបានឆ្លងមេរោគអេដស៍ និងជំងឺកាមរោគដទៃទៀតរួមទាំងតាមរយៈការបង្កើតសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជដោយមានការរក្សាការសម្ងាត់ និងដោយផ្អែកលើសិទ្ធិ ក្រុមមិត្តគាំទ្រមិត្ត ការធ្វើការងារដោយផ្ទាល់ជាមួយគ្រួសារ សហគមន៍ និងសង្គមស៊ីវិល។[65]

### គន្លឹះទី ១៣៖
កម្មវិធីសមាហរណកម្មសម្រាប់ពលករទេសន្តរប្រវេសន៍ដែលវិលត្រឡប់មកវិញ គប្បីពិចារណាលើស្ថានភាពសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសដើមរបស់ពួកគេផងដែរ មិនត្រឹមតែសម្រាប់ខ្លួនពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគ្រួសាររបស់ពួកគេផងដែរ។

### គន្លឹះទី ១៤៖
កសាងភាពជាដៃគូជាមួយទីភ្នាក់ងារ និងស្ថាប័នដទៃទៀត ដើម្បីធានានូវការផ្តល់សេវាគាំទ្រគ្រប់ជ្រុងជ្រោយ និងការបន្តការថែទាំ។[66]

64 ICAT Draft Submission to CEDAW.

65 Ibid

66 Surtees, R ( 2017 ).

# ករណីសិក្សា

## ករណីសិក្សាទី ១[67] ការកំណត់អត្តសញ្ញាណជនរងគ្រោះក្រោយការបង្ក្រាបមួយ

"ហ្វា" គឺជាស្ត្រីវ័យក្មេងម្នាក់ ដែលទីភ្នាក់ងារមួយបានជ្រើសរើស ដោយសន្យាផ្តល់ការងារមួយជាជាងកាត់ដេរនៅរាជធានី។ នាងបានខ្ចីលុយពីមិត្តភក្តិ និងគ្រួសារ ដើម្បីបង់ថ្លៃសម្រាប់អ្នកជ្រើសរើស ប៉ុន្តែនៅពេលដែលនាងបានទៅដល់ទីក្រុង នាងបានដឹងថា "បំណុល" របស់នាងចំពោះទីភ្នាក់ងារជ្រើសរើសបានកើនឡើងជាងទ្វេដង ហើយនាងជាមួយនឹងស្ត្រីដទៃទៀតប្រហែល ២៥នាក់ ត្រូវបានបញ្ចុះបញ្ចូលឱ្យធ្វើការងារនៅក្នុងហាងម៉ាស្សាមួយ ដើម្បីរកលុយបានច្រើនយ៉ាងឆាប់រហ័ស។ នៅពេលដំបូង នាងជឿថា ការងារនោះពិតជាការងារម៉ាស្សាមែន ប៉ុន្តែនៅពេលបន្តិចក្រោយមកនាងបានដឹងយ៉ាងឆាប់រហ័សថា នាងត្រូវផ្តល់សេវាផ្លូវភេទដល់អតិថិជនរបស់នាង។ បន្ទាប់ពីទទួលអតិថិជនទីមួយហើយ នាងមានអារម្មណ៍អាម៉ាស់យ៉ាងខ្លាំង និងមិនអាចគេចទៅណាបាន។ ម្ចាស់ហាងម៉ាស្សាបានប្រាប់នាងថា គ្មានអ្នកណានឹងជួលនាងឱ្យធ្វើជាជាងកាត់ដេរទៀតឡើយពីព្រោះប្រវត្តិធ្វើការងារផ្លូវភេទរបស់នាង។

នៅថ្ងៃមួយ ហាងម៉ាស្សានេះត្រូវបានបង្ក្រាប ហើយ ហ្វា និងស្ត្រី និងកុមារីដទៃទៀតត្រូវបានជួយសង្គ្រោះពីស្ថានភាពដ៏អាក្រក់នោះ។ នគរបាល និងមន្ត្រីស៊ើបអង្កេតដែលបានចូលរួមនៅក្នុងការបង្ក្រាបនោះ ស្ទើរតែជឿយ៉ាងច្បាស់ថា ស្ត្រីទាំងនេះ គឺជាជនរងគ្រោះដោយអំពើជួញដូរ។ មន្ត្រីស៊ើបអង្កេតម្នាក់កំពុងសម្ភាសស្ត្រីទាំងនេះ ហើយការសម្ភាសនេះដំណើរការទៅមិនបានល្អឡើយ។ ហ្វា គឺជាស្ត្រីទីបី ដែលមន្ត្រីស៊ើបអង្កេតនេះនិយាយជាមួយ ដូចស្ត្រីដទៃទៀតដែរ នាងទទូចថា នាងមិនត្រូវបានបង្ខំឱ្យធ្វើការងារនេះឡើយ។

ហ្វា៖ លុយគឺជារឿងល្អ។ ខ្ញុំអាចរកលុយ សម្រាប់ខ្លួនខ្ញុំ និងគ្រួសាររបស់ខ្ញុំ។ ហេតុនេះហើយបានជាខ្ញុំនៅទីនេះ។ ខ្ញុំមានសេរីភាពក្នុងការចេញចូល។ វាជាជម្រើសរបស់ខ្ញុំ។

មន្ត្រីស៊ើបអង្កេត៖ ប៉ុន្តែយើងមានព័ត៌មានដែលអាចទុកចិត្តបានយ៉ាងខ្លាំង ដែលប្រាប់យើងថា អ្នកប្រហែលជាត្រូវបានគេនាំមកទីនេះ ដោយចេតនាក្លែងក្លាយ។ តើអ្នកមិនគិតថា អ្នកមកទីនេះដើម្បីធ្វើអ្វីផ្សេងទេឬ?

ហ្វា៖ ចាស៎ ខ្ញុំគិតថាខ្ញុំនឹងធ្វើជាជាងកាត់ដេរ។ ប៉ុន្តែបន្ទាប់មក ខ្ញុំដឹងថានៅកន្លែងនេះរកលុយបានច្រើនជាង។

មន្ត្រីស៊ើបអង្កេត៖ និងគ្មាននរណាម្នាក់បង្ខំអ្នកឱ្យធ្វើការងារនេះមែនទេឬ? គ្មាននរណាម្នាក់បាននិយាយថា នេះគឺជាវិធីតែមួយគត់ ដែលអាចសងបំណុលរបស់អ្នកបានមែនទេឬ?

ហ្វា៖ ប្រហែលខ្ញុំអាចទទួលបានការជួយច្រើនទៀត ប្រសិនបើខ្ញុំប្រាប់អ្នកថា ខ្ញុំត្រូវបានដាក់ច្រវាក់ជាប់គ្រែជារៀងរាល់យប់ ហើយពួកគេវាយធ្វើបាបខ្ញុំ និងបង្ខំឱ្យខ្ញុំធ្វើការងារនេះ។ ប៉ុន្តែនោះមិនមែនជាការពិតឡើយ។

មន្ត្រីស៊ើបអង្កេត៖ ខ្ញុំគ្រាន់តែចង់បានការពិតប៉ុណ្ណោះ ប៉ុន្តែខ្ញុំបារម្ភថា អ្នកនិយាយរឿងបែបនេះ ដោយសារអ្នកខ្លាច។ អ្នកដឹងទេ ប្រសិនបើរឿងរ៉ាវនានាដូចការនិយាយរបស់អ្នក អ្នកអាចត្រូវវិលត្រឡប់ទៅកាន់គ្រួសាររបស់អ្នកវិញ។ តើនោះគឺជាអ្វីដែលអ្នកចង់បានឬ?

ហ្វា៖ ទេ... ទេ... សូមកុំប្រាប់រឿងរ៉ាវទាំងនេះដល់គ្រួសាររបស់ខ្ញុំ សូមកុំប្រាប់គ្រួសារខ្ញុំថា អ្នករកឃើញខ្ញុំនៅទីនេះ..

67 កែសម្រួលពី "Assisting survivors of human trafficking: Multicultural case studies". Project of the O.L. Pathy Family Foundation. (2017).

## ចំណុចចន្លុលបង្ហាញអំពីការមិនបង្កគ្រោះថ្នាក់

- រឿងរ៉ាវជាច្រើនអាចរឹតត្បិតសេរីភាព រួមទាំងអារម្មណ៍អាម៉ាស់អំពីស្ថានភាពរបស់ខ្លួន។ នេះគឺជាបទពិសោធន៍ទូទៅមួយរបស់ជនរងគ្រោះដោយអំពើជួញដូរ។ បើទោះបីជា ហ្វា មានសេរីភាពក្នុងការមកឬទៅក្តី ក៏នាងពិតជាភ័យខ្លាចថាគ្រួសាររបស់នាងដឹងអំពីរឿងនេះដែរ។

- ហ្វា អាចជឿជាក់ថា នាងគ្មានវិធីណា ដើម្បីវិលត្រឡប់ទៅក្នុងសង្គមវិញបានឡើយ ដោយសារនាងធ្លាប់បានធ្វើការងារជាអ្នករកស៊ីផ្លូវភេទ។ នៅក្នុងករណីនេះ នាងជឿថា វាគឺជាប្រការប្រសើរជាងសម្រាប់នាងក្នុងរយៈពេលវែងដែលត្រូវការពារជនជួញដូរ និងការបន្តរកប្រាក់ចំណូល ដើម្បីគាំទ្រខ្លួននាង និងគ្រួសាររបស់នាង។

- ដោយសារការមួម៉ៅក្នុងចិត្ត មន្ត្រីស៊ើបអង្កេតបានគំរាមកំហែងដោយប្រយោលថា ហ្វា នឹងត្រូវបានបញ្ជូនទៅផ្ទះវិញ ប្រសិនបើនាងមិនសហការ។ ការបញ្ជូននេះអាចកើតឡើង ប៉ុន្តែវិធីនៃការនិយាយបែបនេះ បង្កប់ន័យថា ហ្វា គ្មានអំណាច និងគ្មានជម្រើសដទៃទៀត ដើម្បីប្រើប្រាស់ឡើយ។

- ចាំបាច់ត្រូវចងចាំថា គោលដៅនៅក្នុងការសម្ភាសមិនមែនដើម្បីទទួលបានព័ត៌មានទោះក្នុងតម្លៃណាក៏ដោយនោះទេ ប៉ុន្តែដើម្បីជួយលុបបំបាត់ឧបសគ្គទាំងឡាយដែលរារាំងជនរងគ្រោះមិនឱ្យនិយាយប្រាប់រឿងរ៉ាវរបស់ពួកគេ។ នៅពេលបានកំណត់ឃើញឧបសគ្គទាំងនោះ និងបានព្យាយាមលុបបំបាត់ឧបសគ្គទាំងនោះឱ្យបានច្រើនតាមអាចធ្វើបានហើយ មេធាវី នគរបាល និងអ្នកផ្តល់សេវាត្រូវតែទទួលស្គាល់ និងទទួលយកថា តើការនិយាយឬអត់ គឺជាជម្រើសរើសរបស់ជនរងគ្រោះ។ ការប្រើប្រាស់ល្បិច បញ្ឆោត ឬគំរាមកំហែងជនរងគ្រោះឱ្យនិយាយ មិនមែនជារឿងដែលត្រឹមត្រូវតាមក្រមសីលធម៌ឡើយ។ វិធីសាស្ត្របែបនេះ គឺដូចគ្នានឹងថាមវន្តអំណាចនៃការកេងប្រវ័ញ្ច និងមិនធានានូវព័ត៌មានដ៏ត្រឹមត្រូវឡើយ។

## ករណីសិក្សាទី ២[៦៨] មេធាវី និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល

បុរសមេធាវីស្ម័គ្រចិត្តម្នាក់ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលម្នាក់កំពុងពិភាក្សាគ្នាអំពី ករណីនៃបុរសវ័យក្មេងម្នាក់ ដែលអះអាងថាជាជនរងគ្រោះដោយអំពើជួញដូរ។ គាត់បាននិយាយថា គេបាននាំគាត់មកប្រទេសនេះ នៅពេលគាត់មានអាយុ ១៧ឆ្នាំ ហើយគាត់បានទទួលរងការបង្ខំឱ្យធ្វើពេស្យាចារ ប៉ុន្តែ រឿងរ៉ាវជាច្រើនរបស់គាត់ ដូចជាមិនស្របគ្នាសោះ។

មេធាវី៖ ករណីនេះមិនដំណើរការទៅល្អឡើយ។ យើងមិនអាចទទួលបានរឿងរ៉ាវដោយត្រង់ពីគាត់បានឡើយ។ គាត់ត្រូវយល់ថា គាត់ត្រូវប្រាប់ខ្ញុំអំពីអ្វី ដែលពិតជាបានកើតឡើង ប្រសិនបើខ្ញុំនឹងត្រូវជួយគាត់។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល៖ វានឹងត្រូវការពេលវេលា ដើម្បីកសាងទំនុកចិត្តជាមួយគាត់។ ខ្ញុំបាន និងកំពុងធ្វើការងារជាមួយគាត់អស់រយៈពេលពីរបីសប្តាហ៍ហើយ ហើយទើបតែពេលនេះ គាត់បានចាប់ផ្តើមបើកចំហរ។

មេធាវី៖ ខ្ញុំយល់ ប៉ុន្តែ យើងមិនមានពេលឡើយ។ យើងត្រូវការភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីយកទៅជូននគរបាល ហើយបើពេលវេលាកន្លងផុតទៅកាន់តែច្រើន នោះឱកាសនៃការទទួលបានជោគជ័យកាន់តែស្តួចស្តើងទៅដែរ។ ខ្ញុំដឹងថាខ្ញុំជំរុញគាត់យ៉ាងខ្លាំង ប៉ុន្តែគាត់ត្រូវយល់ថាប្រសិនបើគាត់មិនសហការទេ គាត់នឹងត្រូវគេបញ្ជូនត្រឡប់ទៅផ្ទះវិញ។ នេះមិនមែនជាការគំរាមកំហែងទេ វាជាការពិត។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល៖ ខ្ញុំមិនគិតថា គាត់យល់អំពីមូលហេតុដែលយើងសុំឱ្យគាត់រំឭកឡើងវិញអំពីអ្វីគ្រប់យ៉ាង និងនិយាយប្រាប់យើងយ៉ាងលម្អិតឡើយ។ ការធ្វើបែបនេះពិតជាធ្វើឱ្យគាត់ទទួលរងការប៉ះទង្គិចផ្លូវចិត្តឡើងវិញ។

មេធាវី៖ នៅពេលនេះ គាត់ហាក់ដូចជាកំពុងនិយាយកុហក។ ដំបូង គាត់ប្រាប់ខ្ញុំថា គាត់មកដល់ទីនេះដោយដើរមក បន្ទាប់មក គាត់ប្រាប់ខ្ញុំថា ទេ តាមពិត គាត់ជិះរថយន្តដឹកទំនិញមក។ បន្ទាប់ គាត់ប្រាប់ខ្ញុំថា គាត់បម្រើសេវាដល់អតិថិជន ១៥នាក់ក្នុងមួយថ្ងៃ បន្ទាប់មក គាត់ថា ៧នាក់ និងបន្ទាប់មកទៀត ៣០នាក់។ គាត់បាននិយាយថា គេចាក់សោរបង្ខាំងគាត់ បន្ទាប់មក គាត់ប្រាប់ខ្ញុំអំពីពេលវេលានានា ដែលគាត់បានចេញទៅក្រៅជាមួយមិត្តភក្តិ។ គាត់ប្រាប់ខ្ញុំថា គាត់មានអាយុ ១៧ឆ្នាំ ហើយបន្ទាប់មក គាត់ប្រាប់ខ្ញុំថា គាត់មានអាយុ ២០ឆ្នាំ។ ព័ត៌មានទាំងនេះមិនស្របគ្នាសោះ។ ខ្ញុំមិនដឹងថា តើគាត់កំពុងនិយាយកុហក ដើម្បីការពារនរណាម្នាក់ ឬគាត់ខ្លាចអ្វីនោះទេ ប៉ុន្តែខ្ញុំមិនអាចជួយគាត់ និងក្មេងដទៃទៀតបានឡើយ រហូតដល់ខ្ញុំទទួលបានសាច់រឿងដោយត្រង់។

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល៖ ខ្ញុំពិតជាមិនគិតថា គាត់កំពុងកុហកឡើយ។ ខ្ញុំគិតថា គាត់ភ័ន្តច្រឡំ ឬកំពុងទទួលរងការប៉ះទង្គិចផ្លូវចិត្ត ហេតុនេះការចងចាំរបស់គាត់នៅស្រពិចស្រពិល។ ហើយយើងកំពុងធ្វើការងារតាមរយៈអ្នកបកប្រែ ហើយខ្ញុំគិតថាវាធ្វើឱ្យកាន់តែពិបាកថែមទៀត។

68 កែសម្រួលពី “Assisting survivors of human trafficking: Multicultural case studies”. Project of the O.L. Pathy Family Foundation. (2017).

## ចំណុចចង្អុលបង្ហាញអំពីការមិនបង្កគ្រោះថ្នាក់

- ការប៉ះទង្គិចផ្លូវចិត្តអាចធ្វើឱ្យការចងចាំមានលក្ខណៈស្រពិចស្រពិល និងភ័ន្តច្រឡំ។ មនុស្សជាច្រើន ដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ នឹងមានការពិបាកក្នុងនិយាយប្រាប់អំពីរឿងរ៉ាវយ៉ាងច្បាស់ទៅតាមលំដាប់លំដោយ នៅពេលដំបូង។ ការចងចាំដើរតួនាទីដើម្បីការពារជនរងគ្រោះ ហើយពួកគេនៅចងចាំរូបភាពមួយចំនួនយ៉ាងច្បាស់ ខណៈដែលរូបភាពដទៃទៀតអាចបានបាត់ឈឹងតែម្តង។ ប្រសិនបើជនត្រូវជួញដូរមិនអាចចងចាំ ឬផ្លាស់ប្តូរសាច់រឿង នេះមិនមានន័យថា ពួកគេកំពុងកុហក ឬមិនសហការឡើយ។ ចាំបាច់ត្រូវបង្ហាញភាពអត់ធ្មត់ពាក់ព័ន្ធនឹងបញ្ហាភាពចងចាំ និងមិនត្រូវបង្អាក់ទឹកចិត្តរបស់បុគ្គលទាំងឡាយពីការបន្ថែមសាច់រឿង ឬផ្លាស់ប្តូររឿងរ៉ាវ និងព័ត៌មានលម្អិតអំពីបទពិសោធន៍ដែលពួកគេបានប្រាប់ពីដំបូងឡើយ ដោយសារពួកគេអាចមានការចងចាំឡើងវិញនៅពេលក្រោយ។

- យុវជននេះអាចមកពីវប្បធម៌មួយ ដែលពឹងផ្អែកច្រើនលើសញ្ញា ពាក្យប្រៀបធៀប ការសន្និដ្ឋាន និងបរិបទជុំវិញ ដើម្បីបង្ហាញអត្ថន័យជាជាងពាក្យសម្តី។ ទំនោរនៃការប្រាស្រ័យទាក់ទងដោយប្រយោល អាចមានលក្ខណៈរឹងមាំជាពិសេស នៅពេលដែលកិច្ចសន្ទនានេះពាក់ព័ន្ធនឹងប្រធានបទពិបាក និងប្រកបដោយការឈឺចាប់ដូចជាការប៉ះទង្គិចផ្លូវចិត្ត និងការកេងប្រវ័ញ្ចផ្លូវភេទ។ ក្នុងករណីនេះ យុវជននេះអាចកំពុងព្យាយាមប្រាប់សាច់រឿងពេញលេញរបស់គាត់ ប៉ុន្តែវាធ្វើឱ្យព្រះរាជអាជ្ញាភ័ន្តច្រឡំ។

- ជនរងគ្រោះទំនងជាស្ថិតនៅក្នុងបរិយាកាសភ័យខ្លាច ពោលគឺគាត់ខ្លាចការសងសឹកពីជនជួញដូរ ដោយសារការសហការនេះ ហើយគាត់មិនទុកចិត្តមន្ត្រីអ្នកអនុវត្តច្បាប់ ដោយសារបទពិសោធន៍ពីអតីតកាលនៅក្នុងប្រទេសកំណើតរបស់គាត់។

- សម្ពាធ និងសញ្ញានៃការគំរាមកំហែង និងការបង្ខិតបង្ខំ ដែលមាននៅក្នុងការសម្ភាសន៍ជាមួយមេធាវី អាចធ្វើឱ្យជនរងគ្រោះនឹកឃើញដល់អ្នកជិះជាន់គាត់។ ហេតុនេះ វាមិនមែនរឿងគួរឱ្យភ្ញាក់ផ្អើលទេដែលយុវជននេះមានភាពយឺតយ៉ាវក្នុងការទុកចិត្ត មានះចំពោះការបង្ហាញការពិតទាំងស្រុង ឬភ័ន្តច្រឡំអំពីព័ត៌មានលម្អិតនិងលំដាប់ពេលនៃរឿងរ៉ាវរបស់គាត់។

- គាត់អាចមានអារម្មណ៍មិនមានផាសុកភាពដែលត្រូវសម្ភាសដោយមេធាវីជាបុរស/ស្ត្រី។

- យុវជននេះត្រូវសម្រេចចិត្តថា តើគាត់ចង់ប្រាប់រឿងរ៉ាវរបស់គាត់ទៅដល់មេធាវីដែរឬទេ។ ដើម្បីធ្វើសេចក្តីសម្រេចចិត្តនោះ គាត់ត្រូវយល់អំពីមូលហេតុនៃការសុំឱ្យគាត់និយាយអំពីរឿងរ៉ាវរបស់គាត់ និងលទ្ធផលដែលអាចនឹងកើតឡើង។ ជានិច្ចកាល ការនិយាយ ឬអត់ គឺជាជម្រើសរបស់គាត់។

- យុវជននេះគប្បីទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីធូរស្បើយឡើងវិញ និងឆ្លុះបញ្ចាំងអំពីជំហានបន្ទាប់របស់គាត់។ ប្រសិនបើគាត់សម្រេចចិត្តប្រាប់រឿងរ៉ាវរបស់គាត់ដល់មេធាវី នោះអ្នកផ្តល់ប្រឹក្សាអាចធ្វើការងារជាមួយគាត់ ដើម្បីរៀបចំសេចក្តីបរិយាយរបស់គាត់ឡើងវិញ ដើម្បីឱ្យគាត់អាចនិយាយប្រាប់រឿងរ៉ាវនេះបានកាន់តែច្បាស់ជូនមេធាវី។

69 កែសម្រួលពី "Assisting survivors of human trafficking: Multicultural case studies". Project of the O.L. Pathy Family Foundation. (2017).

## ករណីសិក្សាទី ៣៧ មេធាវីសម្ភាសកុមាររងគ្រោះមួយនាក់

ស៊ូមី ដែលគឺជាមេធាវីម្នាក់ ដែលធ្វើការងារជាមួយទីភ្នាក់ងារមួយ ដែលជួយជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ និយាយថា "ខ្ញុំដឹងថា វាជាការពិបាក ប៉ុន្តែខ្ញុំត្រូវការឱ្យអ្នកប្រាប់ខ្ញុំយ៉ាងជាក់លាក់អំពីអ្វីដែលបានកើតឡើងឱ្យបានលម្អិតតាមដែលអាចធ្វើបាន។" គាត់ឈប់បន្តិច ដើម្បីឱ្យអ្នកបកប្រែ បកប្រែទៅកាន់អតិថិជនរបស់គាត់ ដែលជាកុមារីអាយុ ១៥ឆ្នាំម្នាក់។

កុមារីនេះបានបង្ហាញថា នាងចង់ជួយនៅក្នុងការផ្តន្ទាទោសជនល្មើសរបស់នាង និងមានបំណងប្រាប់រឿងរ៉ាវគ្រប់យ៉ាងដែលបានកើតឡើង។

ស៊ូមីសួរថា "នៅពេលជួបគ្នាលើកមុន អ្នកបានប្រាប់ខ្ញុំជាទូទៅអំពីអ្វីដែលបានកើតឡើង ហើយអ្នកបាននិយាយថា ជនជួញដូរបានប្រើអំពើហិង្សាមកលើអ្នក។ តើអ្នកប្រាប់ខ្ញុំបន្ថែមទៀតអំពើហិង្សានេះបានដែរឬទេ?" គាត់ឈប់បន្តិចម្តងទៀត ដើម្បីឱ្យអ្នកបកប្រែ បកប្រែ។

បន្ទាប់មក កុមារីបានចាប់ផ្តើមនិយាយ។ នាងបាននិយាយយ៉ាងយូរ និងបានចាប់ផ្តើមយំ។ ទោះបីជា ស៊ូមី មិនយល់អំពីសម្តីរបស់នាងក្តី គាត់នៅបន្តទំនាក់ទំនងខ្សែភ្នែកជាមួយកុមារីនេះ និងបង្ហាញភាពអាណិតអាសូរតាមគ្រប់វិធីដែលគាត់អាចធ្វើបាន។

អ្នកបកប្រែនិយាយថា "ខ្ញុំទទួលការវាយដំ ហើយគេបានចងខ្ញុំ។ ពួកគេបង្ខំឱ្យខ្ញុំធ្វើកិច្ចការជាច្រើន ខ្ញុំគិតថា អ្នកដឹងហើយ។"

ស៊ូមីបានងាកទៅកាន់អ្នកបកប្រែ នឹងសួរថា "តើនោះគឺជាអ្វីទាំងអស់ ដែលនាងបាននិយាយឬ? ខ្ញុំគិតថា នាងបាននិយាយលម្អិតច្រើនជាងនេះ។"

អ្នកបកប្រែបាននិយាយថា "ចាស៎ នៅក្នុងភាសារបស់យើង ពាក្យនៅក្នុងភាសារបស់យើងវែងខ្លាំង ហើយយើងត្រូវការប្រើពាក្យជាច្រើន ដើម្បីពន្យល់រឿងតែមួយ។

"ស៊ូមី បានបន្ត "អ្នកបាននិយាយថា ពួកគេបានបង្ខំអ្នកឱ្យធ្វើកិច្ចការជាច្រើន។ តើអ្នកនឹងមានបំណងប្រាប់ខ្ញុំអំពីព័ត៌មានលម្អិតជាក់លាក់អំពីកិច្ចការទាំងនោះដែរឬទេ?"

អ្នកបកប្រែ បានបកប្រែ ហើយកុមារីចាប់ផ្តើមយំ មើលទៅដូចជាច្របូកច្របល់ និងតានតឹងក្នុងចិត្ត។

## ចំណុចចងចាំសំខាន់ៗអំពីការមិនបង្កគ្រោះថ្នាក់

- ចាំបាច់ត្រូវធានាថា ជនរងគ្រោះមានអារម្មណ៍មានផាសុកភាពក្នុងការរំឭកអំពីបទពិសោធន៍របស់ពួកគេជាមួយអ្នកបកប្រែ។ មុនពេលដំណើរការសម្ភាសចាប់ផ្តើម វាជាការល្អ ក្នុងការកសាងទំនុកចិត្តរវាងជនរងគ្រោះ និងអ្នកបកប្រែ រួមទាំងការផ្តល់ពេលខ្លះឱ្យអ្នកបកប្រែណែនាំខ្លួនឯងទៅដល់ជនរងគ្រោះ។

- នៅពេលខ្លះ អ្នកបកប្រែមិនមានអារម្មណ៍សុខស្រួលក្នុងការបកប្រែព័ត៌មានលម្អិតជាក់លាក់ ជាពិសេស ព័ត៌មានលម្អិតពាក់ព័ន្ធនឹងបញ្ហាផ្លូវភេទ ដែលអាចជាបម្រាមបែបប្រពៃណី។ នៅក្នុងករណីដូចករណីនេះ កុមារីនេះអាចដឹងថា អ្នកបកប្រែមានអារម្មណ៍មិនសុខស្រួល និងអាចកែសម្រួលសាច់រឿងរបស់នាង។

- ពាក្យជាក់លាក់អាចមិនមាន ឬអាចពិបាកបកប្រែ។ នៅពេលមានករណីបែបនេះ នៅពេលខ្លួនជនរងគ្រោះប្រាប់សាច់រឿងទៅតាមវិធីដែលសមស្របទៅតាមវប្បធម៌ (ដែលជាញឹកញាប់ មានលក្ខណៈវែងជាង និងត្រូវបានសម្របទៅតាមបរិបទច្រើនជាង) ប៉ុន្តែ វាជាការពិបាកក្នុងភ្ជាប់ទំនាក់ទំនងអត្ថន័យពិតប្រាកដនៃសាច់រឿងនេះតាមរយៈការបកប្រែពាក្យដោយត្រង់ៗណាស់។

- ការបន្ថែមភាគីទីបីនៅក្នុងការសម្ភាសតែងតែជាការពិបាក។ ជនរងគ្រោះអាចមានអារម្មណ៍ប្រឈម និងមានភាពងាយរងគ្រោះកាន់តែខ្លាំង។ ការធ្វើបែបនេះក៏អាចមានផលប៉ះពាល់ចំពោះខ្លឹមសារនៃសេចក្តីបរិយាយរបស់ជនរងគ្រោះផងដែរ។

- ក្នុងគ្រប់វប្បធម៌ទាំងអស់ ទោះបីជាវប្បធម៌ខ្លះមានកម្រិតធ្ងន់ធ្ងរជាងវប្បធម៌ដទៃទៀតក្តី ស្ត្រីអាចទទួលរងការស្តីបន្ទោសចំពោះការក្លាយទៅជាជនរងគ្រោះផ្លូវភេទ។ ប្រសិនបើជនរងគ្រោះបន្ទោសខ្លួនឯង ឬមានអារម្មណ៍ថា អ្នកបកប្រែបន្ទោសនាងចំពោះអ្វីដែលបានកើតឡើង នាងពិតជាមានភាពស្ទាក់ស្ទើរក្នុងការនិយាយដោយបើកចំហរ។

- គន្លឹះសំខាន់មួយសម្រាប់ធ្វើការងារប្រកបដោយប្រសិទ្ធភាពជាមួយអ្នកបកប្រែ គឺមិនត្រូវអនុញ្ញាតឱ្យជនរងគ្រោះនិយាយវែងពេកដោយគ្មានការបកប្រែឡើយ។ អ្នកបកប្រែគប្បីបកប្រែមួយប្រយោគម្តងៗ ហើយគ្រប់ភាគីទាំងអស់ រួមទាំងអ្នកសម្ភាសន៍ផង ចាំបាច់ត្រូវបានរំឭកអំពីបញ្ហានេះជាច្រើនដង នៅទូទាំងកិច្ចសម្ភាសនេះ។

- ប្រសិនបើព័ត៌មានដែលត្រូវបានប្រមូល មានលក្ខណៈរសើបជាពិសេស វាជាការល្អដែលត្រូវធ្វើការងារជាមួយអ្នកបកប្រែជាមុន ដើម្បីធានាថា គាត់យល់អំពីសារៈសំខាន់នៃការបកប្រែចំណុចលម្អិតនីមួយៗ។

- មេធាវី ស៊ូមី គឺជាមេធាវីមានវិជ្ជាជីវៈ និងបង្ហាញភាពអាណិតអាសូរនៅក្នុងការសួរសំណួររបស់គាត់។ គាត់មានការប្រុងប្រយ័ត្ន ដោយមិនបង្ហាញនូវការស្តីបន្ទោសជនរងគ្រោះចំពោះអ្វីដែលបានកើតឡើង ហើយជំនួសវិញ គាត់អនុញ្ញាតឱ្យជនរងគ្រោះនិយាយអំពីអ្វីដែលបានកើតឡើង។

## ករណីសិក្សាទី ៤[70] ចៅក្រមនិយាយជាមួយបុរសរងគ្រោះ

ចៅក្រមកាន់តែមួម៉ៅ។ "ប្រាប់ខ្ញុំម្តងទៀត ហេតុអ្វីបានជាអ្នកមិនចាកចេញតែម្តងទៅ?"

"ខ្ញុំបានប្រាប់លោកហើយ លោកចៅក្រម ពួកគេបានយកលិខិតឆ្លងដែនរបស់ខ្ញុំ។ ខ្ញុំមិនអាចចាកចេញបានទេ។"

ចៅក្រមផ្នែកអន្តោប្រវេសន៍កំពុងស្តាប់បុរសម្នាក់ឈ្មោះ "មួង"។ គាត់ និងមេធាវីកំពុងតែអះអាងថា គាត់ត្រូវបានគេជួញដូរមកប្រទេសនេះក្រោមចេតនាក្លែងក្លាយ។ យោងតាម មួង គាត់បានបង់សោហ៊ុយដល់ឈ្មួញកណ្តាល ដើម្បីរកការងារល្អមួយនៅក្នុងភោជនីយដ្ឋាន។ ផ្ទុយទៅវិញ គាត់បានអះអាងថា គាត់ត្រូវបានគេយកទៅធ្វើជាទាសករនៅក្នុងរោងចក្រកែច្នៃអាហារសមុទ្រទៅវិញ។ គាត់បាននិយាយថា គាត់មិនដែលទទួលបានប្រាក់ឈ្នួលទាល់តែសោះ ចាប់តាំងពីបានចាប់ផ្តើមធ្វើការងារនៅទីនោះពី ១១ខែមុន។ គាត់បានធ្វើការងារជារៀងរាល់ថ្ងៃ នៅក្នុងស្ថានភាពដ៏កខ្វក់ និងដេកនៅក្នុងបន្ទប់ដ៏តូចមួយ ដែលមិនសូវមានខ្យល់ចេញចូលជាមួយមនុស្ស ១៤នាក់ផ្សេងទៀត និងត្រូវគេចាក់សោរនៅពេលយប់។ នៅពេលរោងចក្រនេះស្ថិតក្រោមការស៊ើបអង្កេតពីបទគេចវេសការបង់ពន្ធ និងការបន្លំ ពួកគេបានដោះលែង មួង និងអ្នកដទៃទៀត ដោយមិនផ្តល់ប្រាក់ឈ្នួលដល់ពួកគេឡើយ។

ចៅក្រម៖ "អ្នកមិនត្រូវការលិខិតឆ្លងដែន ដើម្បីចាកចេញពីទីនោះឡើយ។ ហេតុអ្វីបានជាអ្នកមិនចាកចេញពីរោងចក្រនោះនៅថ្ងៃណាមួយទៅ?"

មួង៖ "ខ្ញុំ... ខ្ញុំមិនអាចចាកចេញបានទេ លោកចៅក្រម។"

ចៅក្រម៖ "ហេតុអ្វីមិនអាច? តើមានគេគំរាមកំហែងអ្នកមែនទេ? តើអ្នកនិយាយថា ពួកគេនឹងធ្វើបាបអ្នកមែនទេ? តើពួកគេធ្លាប់ប្រើអំពើហិង្សាលើអ្នកដែរ ឬទេ?"

មួង៖ "ទេ។"

ចៅក្រម៖ "តើពួកគេបានគំរាមកំហែងគ្រួសាររបស់អ្នកនៅផ្ទះមែនទេ?"

មួង៖ "ទេ។ ប៉ុន្តែ ខ្ញុំគ្មានលុយ ហើយខ្ញុំគ្មានឯកសារ។ តើខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច?"

ចៅក្រម៖ "អ្នកអាចដើរចេញពីទីនោះ និងដើរទៅរកនគរបាល និងប្រាប់ពួកគេអំពីអ្វីដែលពួកគេបានធ្វើចំពោះអ្នក។"

មួង៖ "ប៉ុន្តែ បន្ទាប់មក ពួកគេនឹងចាប់ខ្លួនខ្ញុំ។"

ចៅក្រម៖ "ហេតុអ្វី? តើអ្នកកំពុងប្រាប់ខ្ញុំថា អ្នកបានធ្វើខុសច្បាប់ឬ? តើមានមូលហេតុអ្វីមួយ ដែលពួកគេគប្បីចាប់ខ្លួនអ្នក ដែរឬទេ?"

មួង៖ "ដោយសារខ្ញុំមិនមានឯកសាររបស់ខ្ញុំ លោកចៅក្រម។"[71]

70 កែសម្រួលពី "Assisting survivors of human trafficking: Multicultural case studies". Project of the O.L. Pathy Family Foundation. (2017).

71 កែសម្រួលពី "Assisting survivors of human trafficking: Multicultural case studies". Project of the O.L. Pathy Family Foundation. (2017).

## ចំណុចចង្អុលបង្ហាញអំពីការមិនបង្កគ្រោះថ្នាក់

- នៅពេលជនរងគ្រោះបានចូលរួមក្នុងសកម្មភាពអ្វីមួយខុសច្បាប់ ដូចដែលពួកគេជាច្រើនបានចូលរួម បញ្ហានេះបង្កឧបសគ្គយ៉ាងធំចំពោះពួកគេក្នុងការស្វែងរកជំនួយ។ ជនជួញដូរមនុស្សដឹងអំពីបញ្ហានេះ និងរមែងតែងកេងប្រវ័ញ្ចលើការភ័យខ្លាចរបស់ជនរងគ្រោះរបស់ពួកគេ។ ជនរងគ្រោះភាគច្រើនមិនដឹង ឬមិនយល់ថា ពួកគេអាចមានសិទ្ធិទទួលបានឧបាស្រ័យផ្លូវច្បាប់ និងកិច្ចការពារមួយចំនួនឡើយ។

- ចៅក្រមគប្បីដឹងថា វាមិនមែនជាការងាយស្រួលឡើយ សម្រាប់ជនរងគ្រោះដោយអំពើជួញដូរក្នុងការគ្រាន់តែដើរចេញពីស្ថានភាពរបស់ពួកគេ។ ជនដែលត្រូវគេជួញដូរភាគច្រើនមានអារម្មណ៍ដូចជាពួកគេគ្មានការគ្រប់គ្រងលើស្ថានភាពរបស់ពួកគេឥចឹង។ វាជាការធម្មតា ដែលពួកគេមានអារម្មណ៍អស់សង្ឃឹមយ៉ាងខ្លាំង និងកាត់ផ្តាច់ពីសង្គមខាងក្រៅ។ ចាំបាច់ត្រូវយល់អំពីអារម្មណ៍ដ៏ស្មុគស្មាញ ដែលជនដែលត្រូវគេជួញដូរអាចជួបប្រទះ និងបរិបទនយោបាយ និងផ្លូវច្បាប់ពីកន្លែងដែលពួកគេបានចាកចេញមក។

- មួង អាចទទួលរងការកេងប្រវ័ញ្ច ប៉ុន្តែ អាចមិនចង់ប្រាប់តុលាការអំពីរឿងពិតទាំងស្រុង។ ជនរងគ្រោះដោយអំពើជួញដូរជាច្រើន មានភាពអាម៉ាស់ខ្លាំងចំពោះការដែលត្រូវចាញ់ល្បិចកលគេ។ ក្នុងនាមជាបុរសម្នាក់ មួង អាចជឿថា គាត់ត្រូវបង្ហាញខ្លួនឯងក្នុងសភាពរឹងមាំ និងមានការគ្រប់គ្រងលើស្ថានភាពនោះ។ ចៅក្រមគប្បីបើកចំហរចិត្តក្នុងការស្តាប់រឿងរ៉ាវរបស់ មួង ដើម្បីទទួលបានការពិតនៃអង្គហេតុទាំងអស់អំពីស្ថានភាពនោះ។

72 កែសម្រួលពី Surtees, R (2013).

## ករណីសិក្សាទី ៥[72] ការប៉ះទង្គិចផ្លូវចិត្តឡើងវិញក្នុងអំឡុងពេលនៃសវនាការតុលាការ

"គន្ធា" បានចូលរួមនៅក្នុងដំណើរការផ្លូវច្បាប់ចំនួនពីរពាក់ព័ន្ធនឹងបទពិសោធន៍នៃអំពើជួញដូររបស់នាង ក្នុងនោះ ដំណើរការមួយ សម្រាប់ករណីជួញដូរមនុស្ស និងករណីមួយទៀតសម្រាប់ករណីរំលោភសេពសន្ថវៈ។ នាងបាន ស្នើសុំផ្តល់ចម្លើយរបស់នាងជាលក្ខណៈឯកជន ប៉ុន្តែ សំណើរបស់នាងត្រូវបានបដិសេធ។ អង្គការមិនមែន រដ្ឋាភិបាលដែលជួយ គន្ធា បានស្នើសុំបន្ទប់រង់ចាំលក្ខណៈឯកជនមួយសម្រាប់នាង នៅក្នុងអំឡុងពេលនៃការរង់ចាំ សវនាការតុលាការ។ ពួកគេក៏បានរៀបចំឱ្យ គន្ធា ផ្តល់សក្ខីកម្មអំពីករណីទាំងពីរនៅក្នុងថ្ងៃតែមួយផងដែរ ដើម្បី សន្សំពេលវេលា និងកាត់បន្ថយការចំណាយ។ ទោះបីជាយ៉ាងណាក្តី គន្ធា បានទទួលរងការប៉ះទង្គិចផ្លូវចិត្តយ៉ាង ធ្ងន់ធ្ងរ ដោយសារត្រូវតែតាំងជាមួយករណីទាំងពីរនេះនៅក្នុងពេលតែមួយ ព្រមទាំងប្រឈមមុខជាមួយនឹងទាំងជន ជួញដូរ និងជនរំលោភសេពសន្ថវៈលើនាង។

ក្នុងអំឡុងពេលនៃសវនាការ សាច់ញាតិរបស់ចុងចោទ (ជាងសាមសិបនាក់) បានចាប់ផ្តើមចំអកមកលើ គន្ធា ហើយចៅក្រមមិនបានរារាំងអំពើបៀតបៀននោះឡើយ។ ការធ្វើបែបនេះបានធ្វើឱ្យនាងភ័យខ្លាច។ បន្ថែមលើនេះ ចៅក្រមបានសួរ គន្ធា នូវសំណួរផ្ទាល់ខ្លួនមួយចំនួនដែលមិនពាក់ព័ន្ធជាមួយនឹងករណីនេះ។ នាងបានបាត់បង់ ទំនុកចិត្តចំពោះដំណើរការផ្លូវច្បាប់ និងមានការភ័យខ្លាច ដោយសារការគំរាមកំហែងពីសំណាក់ជនជួញដូរ/ជន រំលោភសេពសន្ថវៈ និងគ្រួសាររបស់ពួកគេ។

ចៅក្រម៖ "តើនាងមានមិត្តប្រុស នៅមុនពេលដែលនាងទទួលរងការរំលោភសន្ថវៈ ដែរ ឬទេ?"

គន្ធា៖ "ទេ លោកចៅក្រម..."

ចៅក្រម៖ "តើនាងចូលចិត្តពិធីជប់លៀង និងមានពេលវេលាដ៏រីករាយនៅក្នុងពិធីទាំងនោះដែរ ឬទេ?"

គន្ធា៖ "ទេ លោកចៅក្រម..."

ចៅក្រម៖ "តើអ្នកចូលរួមពាក់សម្លៀកបំពាក់បញ្ចេញសាច់ ដើម្បីទាក់ទាញចំណាប់អារម្មណ៍បុរសដែរ ឬទេ?"

គន្ធា៖ "ទេ ខ្ញុំមិនស្លៀកពាក់បែបនេះទេ លោកចៅក្រម។"

(គេអាចស្តាប់ឮអ្នកចូលរួមនៅក្នុងតុលាការនិយាយខ្លាំងៗថា គន្ធា មិនមែនជាស្រីល្អឡើយ ហើយនាងចូលចិត្តដើរ លេងជាមួយក្មេងប្រុសៗដែលមិនល្អ)។

## ចំណុចចងចាំលបន្ថាញអំពីការមិនបង្កគ្រោះថ្នាក់

- អង្គការមិនមែនរដ្ឋាភិបាលបានព្យាយាមសន្សំពេលវេលា និងការចំណាយលើការធ្វើដំណើររបស់ គន្ធា តាមរយៈការរៀបចំឱ្យនាងផ្តល់សក្ខីកម្មលើករណីទាំងពីរនៅថ្ងៃតែមួយ។ ទោះបីជាយ៉ាងណាក្តី ពួកគេមិនបានពិចារណាអំពីការប៉ះទង្គិចផ្លូវចិត្តដែលអាចកើតឡើង ដែលនាងអាចជួបប្រទះដោយសារការរៀបចំបែបនេះឡើយ ដែលអាចមានឥទ្ធិពលលើដំណើរការធូរស្បើយឡើងវិញរបស់នាង ព្រមទាំងសមត្ថភាពរបស់នាងក្នុងការបន្តចូលរួមនៅកិច្ចដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។

- ព្រះរាជអាជ្ញាដែលតំណាងឱ្យជនរងគ្រោះ គប្បីបានស្នើសុំឱ្យមានការជំនុំជម្រះបិទទ្វារ ដែលមានន័យថា មានតែជនរងគ្រោះ បុគ្គលផ្តល់ការគាំទ្រ និងភាគីចាំបាច់ដទៃទៀតប៉ុណ្ណោះ ដែលបានទទួលការអនុញ្ញាតឱ្យនៅក្នុងបន្ទប់តុលាការ ដូចជាជនត្រូវចោទ និងមេធាវីរបស់ពួកគេ ប្រធានតុលាការ អ្នកប្រតិចារិក អ្នកបកប្រែ។ល។

- តុលាការគប្បីបានការពារអនាមិកភាពរបស់ គន្ធា នៅក្នុងអំឡុងពេលនៃសវនាការ និងធានាថា ព័ត៌មានណាមួយដែលអាចបង្ហាញអត្តសញ្ញាណ ឬអាសយដ្ឋានរបស់នាង មិនត្រូវបានពណ៌នាឡើយ។ ពួកគេគប្បីរៀបចំវិធានការនានា ដើម្បីការពារសុវត្ថិភាព និងសន្តិសុខរបស់ គន្ធា ពីជនល្មើស តាមរយៈវិធានការនានា ដូចជា៖ ការរឹតត្បិតចំនួនមនុស្សនៅក្នុងតុលាការ ដោយអនុញ្ញាតឱ្យមានតែមនុស្សចាំបាច់ប៉ុណ្ណោះ ការអមដំណើរទៅកាន់ និងមកពីអាគារតុលាការ ការប្រើប្រាស់ច្រកចូលដោយឡែកទៅកាន់អាគារតុលាការ កន្លែងរង់ចាំឯកជន។ល។

- ចៅក្រមគប្បីផ្តល់យកចិត្តទុកដាក់ច្រើនជាងនេះចំពោះ គន្ធា ដោយធានាថា នាងមិនមានអារម្មណ៍ទទួលរងការបំភិតបំភ័យ ឬរងគ្រោះសារជាថ្មីដោយសារសវនាការតុលាការឡើយ។ ចៅក្រមគប្បីផ្តល់អន្តរាគមន៍យ៉ាងសកម្មជំនួសមុខ គន្ធា ប្រសិនបើនាងទទួលរងការបៀតបៀន។ ចៅក្រមគប្បីបានបញ្ជាឱ្យសាច់ញាតិរបស់ជនចុងចោទ និងបុគ្គលិកមិនចាំបាច់ដទៃទៀតចាកចេញពីបន្ទប់តុលាការ នៅពេលដែលជនរងគ្រោះកំពុងផ្តល់សក្ខីកម្ម។ ចៅក្រមមិនគប្បីសួរសំណួរមិនពាក់ព័ន្ធ ឬសំណួរផ្ទាល់ខ្លួនដែលមិនពាក់ព័ន្ធនឹងករណីនេះឡើយ។

73 កែសម្រួលពី "Assisting survivors of human trafficking: Multicultural case studies". Project of the O.L. Pathy Family Foundation. 2017.

## ករណីសិក្សាទី ៦[73] មេធាវីកំពុងនិយាយទៅកាន់កុមាររងគ្រោះ

លីហ្សា ដែលជាមេធាវីសម្រាប់កុមាររងគ្រោះដោយអំពើជួញដូរផ្លូវភេទ បាននិយាយថា "ខ្ញុំមិនអាចប្រាប់អ្នកអំពីអ្វីដែលត្រូវធ្វើបានឡើយ។ អ្នកមានជម្រើសអំពីថា តើអ្នកនិយាយជាមួយនគរបាល ឬអត់។ គ្មាននរណាម្នាក់បង្ខំអ្នកឡើយ ប៉ុន្តែប្រសិនបើអ្នកជួបជាមួយនគរបាល វានឹងជួយដល់ករណីរបស់អ្នក និងជួយដល់អ្នកដទៃទៀត ដែលកំពុងបន្តស្ថិតនៅក្នុងស្ថានភាពដូចគ្នាជាមួយអ្នក។"

អតិថិជនរបស់លីហ្សាឈ្មោះ ម៉ៃ កំពុងសម្លឹងមើលទៅក្រោមគ្រប់ពេល និងបាននិយាយថា "ខ្ញុំគិតថា អ្នកដឹងច្បាស់ណាស់។ អ្នកជាមេធាវី។ សូមប្រាប់ខ្ញុំអំពីអ្វីដែលខ្ញុំគួរធ្វើ។"

"វាជាជម្រើសរបស់អ្នក ប៉ុន្តែខ្ញុំគិតថា អ្នកគួរនិយាយជាមួយនគរបាល។" ម៉ៃ ងក់ក្បាល ហើយភ្នែករបស់នាងនៅតែសម្លឹងទៅក្រោម។

លីហ្សា មានអារម្មណ៍មិនច្បាស់អំពីបញ្ហានេះឡើយ។ កាលពីសប្តាហ៍មុន ម៉ៃ បាននិយាយថា នាងចង់និយាយជាមួយនគរបាល ប៉ុន្តែបន្ទាប់មក នៅក្នុងការសម្ភាសជាមួយនគរបាល នាងស្ទើរតែគ្មាននិយាយអ្វីទាំងអស់។ គាត់មិនច្បាស់អំពីអ្វីដែលម៉ៃត្រូវការ ឬចង់បានឡើយ។ គាត់មិនច្បាស់ថា តើមានការពិចារណាយ៉ាងគ្រប់គ្រាន់ទៅលើគ្រប់បញ្ហាសុវត្ថិភាពទាំងអស់ដែរឬទេ។ គាត់កំពុងគិតថា ការធ្វើឱ្យមានតុល្យភាពរវាងការផ្តល់ដំបូន្មានដល់ ម៉ៃ និងការធានាថានាងមានលំហសម្រាប់ធ្វើសេចក្តីសម្រេចចិត្តរបស់ខ្លួននាងផ្ទាល់ ស្ទើរតែពុំអាចធ្វើទៅបានឡើយ។

"អូខេ ម៉ៃ យើងនឹងធ្វើអ្វីគ្រប់យ៉ាងដែលអ្នកចង់បាន។ ប៉ុន្តែ ខ្ញុំចង់ឱ្យអ្នកយល់ច្បាស់ថា អ្នកគឺជាមេរបស់ខ្ញុំ។ ខ្ញុំអាចប្រាប់អ្នកនូវអ្វីដែលខ្ញុំគិតថាល្អបំផុត ប៉ុន្តែអ្នកត្រូវប្រាប់ខ្ញុំអំពីអ្វីដែលត្រូវធ្វើ។"

ម៉ៃ បានញញឹម និងងើបមុខបន្តិច បន្ទាប់មកសម្លឹងទៅក្រោមវិញម្តងទៀត និងងក់ក្បាល។

លីហ្សា បាននិយាយបន្ត "ការនិយាយជាមួយនគរបាល គឺជារឿងល្អ ប៉ុន្តែ អ្នកមិនចាំបាច់ត្រូវតែនិយាយជាមួយពួកគេឡើយ។ អ្នកមានអាយុក្រោម ១៨ឆ្នាំ ដែលមានន័យថា អ្នកមានសិទ្ធិ ហើយអ្នកអាចស្នាក់នៅទីនេះ និងទៅរៀនបាន បើទោះបីជាអ្នកមិននិយាយក៏ដោយ។ តើអ្នកយល់ទេ ?"

"ចាស៎។"

"ហេតុនេះ តើអ្នកចង់ធ្វើអ្វី ?"

"តើអ្នកគិតយ៉ាងម៉េច ? ខ្ញុំនឹងធ្វើតាមអ្វីដែលណែនាំឱ្យខ្ញុំធ្វើ។"

## ចំណុចចង្អុលបង្ហាញអំពីការមិនបង្កគ្រោះថ្នាក់

- បន្ទាប់ពីកំណត់អត្តសញ្ញាណកុមាររងគ្រោះភ្លាម អាជ្ញាធរត្រូវចាត់តាំងអាណាព្យាបាលដើម្បីអមដំណើរកុមារនៅក្នុងកិច្ចដំណើរការទាំងមូល រហូតដល់ដំណោះស្រាយយូរអង្វែង ដែលជាឧត្តមប្រយោជន៍របស់កុមារ ត្រូវបានកំណត់ និងអនុវត្ត។ នៅក្នុងសេណារីយ៉ូនេះ វាមិនច្បាស់ទេថា តើ ម៉ៃ មានឪពុក ឬម្តាយ ឬមានអាណាព្យាបាលដែលត្រូវបានចាត់តាំងដើម្បីអមដំណើរនាងនៅទូទាំងកិច្ចដំណើរការនេះ ដែរឬទេ។

- មេធាវី លីហ្សា កំពុងព្យាយាមធ្វើរឿងដ៏ត្រឹមត្រូវ តាមរយៈការផ្តល់ភាពអង់អាចដល់ ម៉ៃ និងអនុញ្ញាតឱ្យនាងជ្រើសរើសជម្រើសរបស់នាងផ្ទាល់។ គាត់បង្ហាញជម្រើសមួយចំនួនទៅដល់ ម៉ៃ និងបានប្រាប់នាងអំពីសិទ្ធិរបស់នាង។

- ប៉ុន្តែ លីហ្សា កំពុងមើលរំលងសារប្រយោលដែលមិនបញ្ចេញតាមពាក្យសម្តីរបស់ ម៉ៃ។ គាត់បានចាំស្តាប់ពាក្យសម្តីរបស់ ម៉ៃ ដែលប្រាប់គាត់អំពីអ្វីដែលនាងត្រូវការជាជាងពិនិត្យមើលអាកប្បកិរិយារបស់នាងជាមួយនគរបាល និងភាសាកាយវិការរបស់នាងនៅក្នុងពេលសម្ភាសន៍។

- លីហ្សា ហាក់បីដូចជាមិនយល់ថា នៅក្នុងវប្បធម៌របស់ ម៉ៃ ការបង្ហាញអំពីតម្រូវការដោយផ្ទាល់អាចមិនមែនជារឿងសមគួរឡើយ។ នៅក្នុងគ្រួសារ និងសហគមន៍របស់ ម៉ៃ តម្រូវការរបស់អ្នកគប្បីត្រូវបានលើកឡើងដោយនរណាម្នាក់ផ្សេងទៀត។ ហេតុនេះ ម៉ៃ ពិតជាមានអារម្មណ៍មិនសុខស្រួល និងព្រួយបារម្ភអំពីការចាត់ទុកថា នាងគិតតែពីខ្លួនឯង គ្មានការគោរព និងគ្មានភាពដឹងគុណ។

- លីហ្សា គប្បីយកចិត្តទុកដាក់បន្ថែមទៀតចំពោះភាពខុសគ្នានៃអាយុរវាងគាត់ និង ម៉ៃ។ នៅក្នុងវប្បធម៌របស់ ម៉ៃ នាងត្រូវបានរំពឹងថា ត្រូវអនុញ្ញាតឱ្យមនុស្សដែលមានវ័យច្រើនជាងនាងធ្វើសេចក្តីសម្រេចចិត្ត ហើយនាងចាត់ទុក លីហ្សា ជាបងស្រីម្នាក់។ ហេតុនេះ នាងត្រូវបង្ហាញដល់ លីហ្សា ថា នាងគោរពដំបូន្មាន និងមតិយោបល់របស់គាត់។ នៅពេលដែល លីហ្សា ព្យាយាមផ្លាស់ប្តូរថាមវន្តនៃអំណាច ម៉ៃ ក៏ញញឹម។ ការញញឹមនេះអាចមានន័យច្រើន គិតចាប់អំពីអំណរគុណ រហូតដល់អារម្មណ៍មិនសុខស្រួលដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់។